UN GLOBAL STUDY
ON CHILDREN DEPRIVED OF LIBERTY

## របាយការណ៍លទ្ធផល

# ពិធីផ្សព្វផ្សាយថ្នាក់ជាតិនៅកម្ពុជា អំពីការសិក្សាស្រាវជ្រាវជាសកល ស្តីពីកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាព

| | |
|---|---|
| កាលបរិច្ឆេទ និង ពេលវេលា៖ | ថ្ងៃព្រហស្បតិ៍ ទី២២ ខែមេសា ឆ្នាំ២០២១ ម៉ោង ២:០០ - ៤:០០ រសៀល |
| ទីកន្លែង៖ | តាមប្រព័ន្ធអនឡាញ |
| ភាសា៖ | ខ្មែរ និង អង់គ្លេស (ដោយមានការបកប្រែប្រដេញ) |

unicef for every child · Child Rights Coalition Cambodia · Legal Aid of Cambodia · AYRG · CAN · CYMCR · Justice With Children · Terre des hommes – Helping children worldwide. · Global Campus of Human Rights

## មាតិកា


| | |
|---|---|
| សេចក្ដីផ្ដើម | ៣ |
| ក្រុមអង្គការរៀបចំពិធីផ្សព្វផ្សាយ | ៣ |
| របៀបវារៈ | ៤ |
| ការត្រៀមរៀបចំ | ៥ |
| សេចក្ដីសង្ខេបស្ដីពីពិធីផ្សព្វផ្សាយថ្នាក់ជាតិ | ៨ |
| អ្នកចូលរួម | ១៦ |
| ជំហានបន្ទាប់ | ១៧ |
| ឧបសម្ពន្ធ | ១៨ |


## ពាក្យកាត់

| | | |
|---|---|---|
| ក.ជ.ក. | ៖ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ក.យ. | ៖ | ក្រសួងយុត្តិធម៌ |
| ម.ផ. | ៖ | ក្រសួងមហាផ្ទៃ |
| ស.អ.យ. | ៖ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា |
| FCF | : | Family Care First |
| LAC | : | Legal Aid of Cambodia |
| LICADHO | : | Cambodian Leagues for the Promotion and Defense for Human Rights |
| OHCHR | : | Office of the High Commissionner for Human Rights |
| UNICEF | : | United Nations Children’s Fund |

# សេចក្ដីផ្ដើម ១

ការសិក្សាស្រាវជ្រាវជាសកលស្ដីពីការដកហូតសិទ្ធិសេរីភាពកុមារ (ការសិក្សាជាសកល) ដែលបានផ្សព្វផ្សាយកាលពីខែវិច្ឆិកា ឆ្នាំ២០១៩ ផ្ដល់លទ្ធផលដ៏សំខាន់ទាក់ទងនឹងការដកហូតសិទ្ធិសេរីភាពកុមារនៅជុំវិញពិភពលោក ដោយភ្ជាប់ជាមួយអនុសាសន៍ដ៏រឹងមាំមួយចំនួនសម្រាប់អនុវត្តដើម្បីដោះស្រាយស្ថានភាពទាំងនោះ។ រយៈពេលមួយឆ្នាំកន្លះមកនេះ ការសិក្សាជាសកលត្រូវបានផ្សព្វផ្សាយនៅក្នុងតំបន់និងបណ្ដាលប្រទេសមួយចំនួន ដោយមានកិច្ចសហកាគ្នារវាងរដ្ឋាភិបាល និង សង្គមស៊ីវិល ដើម្បីពង្រឹងការបង្ការនិងការឆ្លើយតបទៅនឹងស្ថានភាពដែលនាំឱ្យមានការដកហូតសិទ្ធិសេរីភាពកុមារ។

ការសិក្សាជាសកលគ្របដណ្ដប់លើកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាពក្នុងស្ថានភាពមួយចំនួនរួមមានដូចជាអនីតិជនទំនាស់នឹងច្បាប់ កុមាររស់នៅជាមួយម្ដាយក្នុងពន្ធនាគារ និង កុមាររស់នៅក្នុងមណ្ឌល។ នៅក្នុងបរិបទកម្ពុជា ស្ថានភាពនេះរួមមានដូចជា កុមារក្នុងពន្ធនាគារ មណ្ឌលថែទាំជំនួស (ដូចជាមណ្ឌលកុមារកំព្រា) មណ្ឌលស្ដារនីតិសម្បទា និងមណ្ឌលសង្គមកិច្ចមួយចំនួន។ ការសិក្សាជាសកលបញ្ជាក់យ៉ាងច្បាស់ថា ការដកហូតសិទ្ធិសេរីភាពកុមារ គឺជាការដកហូតកុមារភាព និងជាទម្រង់នៃអំពើហិង្សាជាប្រព័ន្ធទៅលើកុមារ។

ការផ្សព្វផ្សាយថ្នាក់ជាតិនៅកម្ពុជាអំពីការសិក្សាជាសកលធ្វើឡើងដោយមានគោលបំណងដូចខាងក្រោម៖

- ដើម្បីពន្យល់ពីលទ្ធផលសំខាន់ៗ និងអនុសាសន៍មួយចំនួននៃការសិក្សាជាសកល ជូនរាជរដ្ឋាភិបាលកម្ពុជា អង្គការសង្គមស៊ីវិល និង សាធារណៈជនទូទៅ
- ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាពនៅកម្ពុជា និង ដើម្បីផ្ដល់ឱកាសដល់កុមារ និងសង្គមស៊ីវិល បញ្ចេញមតិយោបល់ តម្រូវការ និង សំណើទៅកាន់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ
- ដើម្បីស្នើឱ្យរដ្ឋាភិបាលសំដែងការប្ដេជ្ញាចិត្តក្នុងការបង្ការទប់ស្កាត់និងឆ្លើយតបទៅនឹងការដកហូតសិទ្ធិសេរីភាពនៅកម្ពុជា និង
- ដើម្បីផ្ដួចផ្ដើមកិច្ចពិភាក្សាដែលនឹងអនុញ្ញាតឱ្យមានការបញ្ចូលអនុសាសន៍នៃការសិក្សាជាសកលនេះទៅក្នុងការងាររបស់រដ្ឋាភិបាល សង្គមស៊ីវិល និង ស្ថាប័នពាក់ព័ន្ធ។

# ក្រុមអង្គការរៀបចំពិធីផ្សព្វផ្សាយ ២

គណៈកម្មាធិការរៀបចំពិធីផ្សព្វផ្សាយថ្នាក់ជាតិនៅកម្ពុជាអំពីការសិក្សាជាសកលនេះ រួមមានភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការក្នុងស្រុក និង អង្គការអន្តរជាតិ ដូចខាងក្រោម៖

- មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (យូនីសេហ្វ)
- អង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា
- អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ដែលជាសមាជិកនៃក្រុមអង្គការប្រឹក្សាយោបល់ដល់ការសិក្សាជាសកល[១]
- បណ្ដាញដែលដឹកនាំដោយកុមារនិងយុវជន ដោយរួមមានក្រុមតំណាងយុវវ័យនិងយុវជន បណ្ដាញកុមារអ្នកតស៊ូមតិ សមាគមចលនាកុមារនិងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ
- កម្មវិធីគំនិតផ្ដួចផ្ដើមជាសកលស្ដីពីយុត្តិធម៌កុមារ ដែលតំណាងដោយអង្គការ Terre deshommes
- សាកលវិទ្យាល័យសិទ្ធិមនុស្ស

---

១ ក្រុមអង្គការប្រឹក្សាយោបល់ដល់ការសិក្សាស្រាវជ្រាវជាសកលស្ដីពីការដកហូតសិទ្ធិសេរីភាពកុមារ គឺមានសមាជិកអង្គការសង្គមស៊ីវិលចំនួន១៧០ នៅជុំវិញពិភពលោក ដែលបង្កើតឡើងដោយអង្គការការពារកុមារអន្តរជាតិ និងអង្គការឃ្លាំមើលសិទ្ធិមនុស្ស។ ក្រុមអង្គការប្រឹក្សាយោបល់ គឺជាដៃគូសំខាន់មួយក្នុងការផ្ដល់យោបល់និងការបញ្ចប់ការសិក្សាជាសកល រួមទាំងការអនុវត្តនិងការតាមដានផងដែរ។ អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា គឺជាអង្គការមួយនៃអង្គការមួយចំនួនតូចនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកខាងកើតដែលបានចូលជាសមាជិកនៃក្រុមអង្គការប្រឹក្សាយោបល់។

# ៣ របៀបវារៈ

| ពេលវេលា | កម្មវិធី | វាគ្មិន |
|---|---|---|
| ២:០០-២:១០ | **កិច្ចចាប់ផ្តើម** | អ្នកកាន់កម្មវិធី៖ **ប្អូនបញ្ញា** តំណាងកុមារនៃបណ្តាញដែលដឹកនាំដោយកុមារនិងយុវជន |
| ២:១០-២:១៥ | **ចំណាប់អារម្មណ៍បើក** | **លោកស្រី** Najat Maalla M'jid, តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកអំពើហិង្សាលើកុមារ |
| ២:១៥-២:២០ | **សុន្ទរកថាបើក** | **ឯ.ឧ. ធូ ស៊ីន** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) |
| ២:២០-២:៤០ | **លទ្ធផលសំខាន់ៗ នៃការសិក្សាជាសកល** | **លោកសាស្ត្រាចារ្យ** Manfred Nowak, អ្នកជំនាញឯករាជ្យ |
| | **សំឡេងសង្គមស៊ីវិល** | |
| ២:៤០-៣:០០ | • កុមារត្រូវបានដកហូតសិទ្ធិសេរីភាពក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងកុមារតាមម្តាយក្នុងពន្ធនាគារ | **លោក ឈិន សៃ** អនុប្រធានអង្គការ This Life Cambodia |
| ៣:០០-៣:២០ | • កុមារត្រូវបានដកហូតសិទ្ធិសេរីភាពក្នុងមណ្ឌលថែទាំ[២] | **លោក លាង ឡូ** ប្រធានផ្នែកកិច្ចការពារកុមារនៃអង្គការ Save the Children |
| | **សំឡេងកុមារ** | |
| ៣:២០-៣:៣០ | • បទពិសោធន៍របស់យុវជនអាយុ១៨ឆ្នាំ ដែលធ្លាប់ជាប់ឃុំក្នុងពេលជាអនីតិជន | **ប្អូន សុក** (ឈ្មោះដាក់ឱ្យក្រៅ) |
| ៣:៣០-៣:៤០ | • សេចក្តីថ្លែងការណ៍រួមរបស់បណ្តាញដែលដឹកនាំដោយកុមារនិងយុវជន | **ប្អូន អុយ** តំណាងកុមារនៃបណ្តាញដែលដឹកនាំដោយកុមារនិងយុវជន |
| ៣:៤០-៣:៤៥ | **ការឆ្លើយតបរបស់រដ្ឋាភិបាល** ការឆ្លើយតបទៅនឹងសំឡេងរបស់កុមារ | **ឯ.ឧ. ធូ ស៊ីន** រដ្ឋលេខាធិការ ក្រសួង ស.អ.យ |
| ៣:៤៥-៣:៥៥ | **សុន្ទរកថាបិទ** | **លោកស្រី** Foroogh Foyouzat, តំណាងអង្គការ UNICEF ប្រចាំកម្ពុជា |
| ៣:៥៥-៤:០០ | **ការបិទកម្មវិធី** | គណៈកម្មាធិការរៀបចំ |

## ការអញ្ជើញចូលរួមក្នុងកិច្ចប្រជុំបន្ទាប់

| | |
|---|---|
| ៤:១៥-៥:១៥ | កិច្ចប្រជុំត្រៀមរៀបចំសន្និសីទពិភពលោក២០២១ស្តីពីយុត្តិធម៌អនីតិជនឬកុមារ |

២ ក្នុងពេលពិធីផ្សព្វផ្សាយ បទបង្ហាញនេះត្រូវបានធ្វើឡើងក្រោយនាទីសំឡេងកុមារ ដោយសារបញ្ហាប្រព័ន្ធអ៊ីនធឺណែត។

# ការត្រៀមរៀបចំ ៤

**ការត្រៀមរៀបចំជាទូទៅសម្រាប់ពិធីផ្សព្វផ្សាយនេះ មានការចូលរួមសម្របសម្រួលពីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ដែលជាសមាជិកនៃក្រុមអង្គការប្រឹក្សាយោបល់ដល់ការសិក្សាជាសកល ហើយការត្រៀមរៀបចំនេះត្រូវបានបែងចែកជាប្រាំផ្នែកសម្រាប់ឱ្យសមាជិកផ្សេងទៀតចូលរួមជួយ។**

## ១. ការពិគ្រោះយោបល់ជាមួយកុមារ

ការពិគ្រោះយោបល់ជាមួយកុមារនិងយុវជន ត្រូវបានដឹកនាំដោយបណ្តាញកុមារនិងយុវជន និងអង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា។ ដោយមានកិច្ចសហការរវាងគណៈកម្មាធិការដឹកនាំរបស់បណ្តាញកុមារនិងយុវជន និងក្រុមគាំទ្រយុវជន និងកុមារនៃអង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា ការពិគ្រោះយោបល់នៅមុនពេលពិធីផ្សព្វផ្សាយ ត្រូវបានធ្វើឡើងជាមួយកុមារនិងយុវជននៅក្នុងប្រទេសកម្ពុជា។ គោលដៅគឺចង់បានយោបល់ទាំងអ្នកមាន និងមិនធ្លាប់មានបទពិសោធន៍ត្រូវបានគេដកហូតសិទ្ធិសេរីភាពឬជាប់ឃុំ ដើម្បីប្រមូលយោបល់ផ្ទាល់ខ្លួននិងដើម្បីស្វែងយល់ពីការយល់ឃើញរបស់ពួកគេទាក់ទងនឹងការដកហូតសិទ្ធិសេរីភាពរបស់កុមារ ឬការជាប់ឃុំ។

ការពិគ្រោះយោបល់នៅមុនពេលពិធីផ្សព្វផ្សាយ ត្រូវបានធ្វើឡើងអស់រយៈពេលមួយខែកន្លះ ដោយរាប់ទាំងការធ្វើអង្កេតតាមប្រព័ន្ធអនឡាញជាភាសាខ្មែរនិងអង់គ្លេស ដែលត្រូវបានផ្សព្វផ្សាយទូលំទូលាយតាមបណ្តាញមួយចំនួន ហើយក្រៅពីនេះក៏មានការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលដែលធ្វើការជាមួយកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាព និងការសិក្សាលើឯកសារពាក់ព័ន្ធនឹងការលើកឡើងរបស់កុមារ។ ការពិគ្រោះយោបល់ជាក្រុមឬបុគ្គលក៏បានគ្រោងធ្វើផងដែរ ប៉ុន្តែត្រូវបានខកខានដោយសារស្ថានភាពកូវីដ១៩ ដែលមិនអាចឱ្យយើងធ្វើទៅបានជាមួយអនីតិជនក្នុងពន្ធនាគារនិងកន្លែងឃុំឃាំងផ្សេងទៀត។ ក៏ប៉ុន្តែ យោបល់របស់កុមារមួយចំនួនត្រូវបានទទួលតាមរយៈអង្គការដៃគូមួយចំនួន។

ការធ្វើអង្កេតតាមប្រព័ន្ធអនឡាញ បានផ្តោតលើបញ្ហាប្រឈមរបស់កុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាព កត្តាដែលជួយឱ្យពួកគេជំនះលើការលំបាកនានា ផលវិបាកដែលកើតចេញពីការដូតសិទ្ធិសេរីភាព និង បញ្ហាមួយចំនួនដែលពួកគេចង់ឱ្យរដ្ឋាភិបាលជួយផ្លាស់ប្តូរក្នុងចំណោមបញ្ហាដទៃទៀត។ ការអង្កេតនោះត្រូវបានបំពេញដោយកុមារនិងយុវជនចំនួន៨៩នាក់ ដែលក្នុងនោះមាន ១១នាក់ធ្លាប់មានបទពិសោធន៍ជាប់ឃុំ ២៥នាក់ បានអះអាងថាបានស្គាល់អ្នកដែលធ្លាប់ជាប់ឃុំក្នុងវ័យជាអនីតិជន។ អ្នកឆ្លើយសំណួរចំនួនពាក់កណ្តាល ជាកុមារអាយុក្រោម១៨ឆ្នាំ ហើយពាក់កណ្តាលទៀតមានអាយុចន្លោះពី១៨ទៅ២៥ឆ្នាំ។ ចំនួនតិចជាង១/៣នៃអ្នកឆ្លើយសំណួរជានារីភេទ ប្រហែល ២/៣ជាបុរស ហើយក្រៅពីនោះស្នើសុំមិនបញ្ជាក់ភេទ។ អ្នកឆ្លើយសំណួររស់នៅក្នុងខេត្ត យ៉ាងហោចណាស់ចំនួន៩ខេត្តក្នុងប្រទេស រាប់ទាំងរាជធានីភ្នំពេញ ខេត្តភាគខាងត្បូងនៃប្រទេស ភាគខាងជើង និង តំបន់ភាគពាយ័ព្យ។

ការសិក្សាលើឯកសារពាក់ព័ន្ធ ត្រូវបានធ្វើឡើងដោយផ្អែកលើឯកសារដែលសរសេរទាក់ទងនឹងបញ្ហាប្រឈមរបស់កុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាព ដែលក្នុងនោះមានឯកសារចំនួន៩ត្រូវបានដកស្រង់ដាក់បញ្ចូលក្នុងសេចក្តីថ្លែងការណ៍រួមខាងក្រោម។ ឯកសារទាំងនោះត្រូវបានរៀបចំដោយអង្គការ This Life Cambodia អង្គការសម្ពន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្សលីការដូ (LICADHO) អង្គការសម្ពន្ធចាប់ដៃ ហើយឯកសារភាគច្រើនត្រូវបានបោះពុម្ពផ្សាយក្នុងអំឡុង៥ឆ្នាំមុន ហើយឯកសារដែលចំណាស់ជាងគេគឺបោះពុម្ពផ្សាយក្នុងឆ្នាំ២០១៣។ ឯកសារទាំងនោះបានសរសេរពីការលើកឡើងរបស់កុមារយ៉ាងហោចណាស់ ២៣៧នាក់ ដែលត្រូវបានដកហូតសិទ្ធិសេរីភាពនៅក្នុងស្ថានភាពផ្សេងៗ ដូចជាក្នុងពន្ធនាគារ មណ្ឌល និង កន្លែងផ្សេងទៀត។

ការលើកឡើងទាំងអស់របស់កុមារត្រូវបានដាក់បញ្ចូលក្នុងសេចក្តីថ្លែងការណ៍ស្តីពីការដកហូតសិទ្ធិសេរីភាពរបស់កុមារនៅកម្ពុជា ដែលរៀបចំដោយបណ្តាញដែលដឹកនាំដោយកុមារនិងយុវជន ហើយដែលត្រូវបានអានជាភាសាខ្មែរដោយអ្នកតំណាងកុមារមួយរូបនៅក្នុងពិធីផ្សព្វផ្សាយថ្នាក់ជាតិនោះ។ សេចក្តីថ្លែងការណ៍ទាំងស្រុងត្រូវបានផ្សព្វផ្សាយក្រោយពេលបញ្ចប់ពិធីនេះ និងត្រូវបានភ្ជាប់ជាឧបសម្ពន្ធនៃរបាយការណ៍លទ្ធផលពិធីនេះ។

បន្ថែមលើនេះ មានវីដេអូខ្លីមួយដែលផលិតដោយអង្គការ This Life Cambodia លើកឡើងពីប្រវត្តិរបស់ប្អូន

សុក (ឈ្មោះដាក់ឱ្យ) អាយុ១៨ឆ្នាំ ដែលធ្លាប់ជាប់ឃុំក្នុងពន្ធនាគារកាលជាអនីតិជន។ ដោយផ្អែកតាមការណែនាំរបស់គណៈកម្មាធិការរៀបចំ អង្គការ This Life Cambodia បានផលិតខ្សែវីដេអូខ្លីនេះ ដោយគោរពតាមគោលការណ៍ការពារសិទ្ធិកុមារ។ ប្អូនសុក ត្រូវបានផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ឆ្លើយនឹងសំណួរដោយខ្លួនឯង ហើយ This Life Cambodia បានធ្វើការជាមួយ សុក អស់រយៈពេលជាងមួយខែដើម្បីរៀបចំថតនិងកែសម្រួលខ្សែវីដេអូខ្លីនេះឱ្យមានលក្ខណៈរក្សាភាពដើម មានឥទ្ធិពល ទាក់ទាញចំណាប់អារម្មណ៍ និងសុវត្ថិភាព។

មុនពេលពិធីផ្សព្វផ្សាយថ្នាក់ជាតិនេះ កុមារា បញ្ញា ដែលជាអ្នកកាន់កម្មវិធី និង កុមារា អ៊ុយ ត្រូវបានត្រៀមសម្រាប់ចូលរួមក្នុងពិធីនេះ ដើម្បីឱ្យពួកគាត់យល់ច្បាស់ពីគោលការណ៍ការពារសិទ្ធិកុមារ ហើយត្រៀមខ្លួនជាស្រេចក្នុងការបំពេញតួនាទីរបស់ខ្លួនក្នុងពិធិនេះ។

## ២. ការសម្របសម្រួលជាមួយរដ្ឋាភិបាល

ការសម្របសម្រួលដើម្បីឱ្យមានការចូលរួមពីក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាល ត្រូវបានដឹកនាំដោយ UNICEF។ ពង្រៀងសេចក្តីថ្លែងការណ៍រួមរបស់អន្តរក្រសួងត្រូវបានធ្វើឡើងជាភាសាអង់គ្លេស និង ខ្មែរ ហើយត្រូវបានដាក់ជូនក្រសួងមហាផ្ទៃ (ម.ហ) ក្រសួងយុត្តិធម៌ (ក.យ) និង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ.) ដើម្បីពិនិត្យសម្រាប់អនុម័ត។ សេចក្តីព្រាងនេះអមដោយលិខិតស្នើសុំរបស់អ្នកជំនាញឯករាជ្យ គឺលោកសាស្ត្រាចារ្យ Manfred Nowak ដែលជាអ្នកដឹកនាំការសិក្សាជាសកល ក្នុងនាមសាកលវិទ្យាល័យសិទ្ធិមនុស្ស និងគណៈកម្មាធិការរៀបចំ។ បន្ទាប់មក UNICEF បានផ្ញើលិខិតតាមដានមួយជូនក្រសួង ស.អ.យ. ដោយស្នើសុំក្រសួងនេះជួយសម្របសម្រួលជាមួយក្រសួងពីរផ្សេងទៀត ដើម្បីឈានទៅអនុម័តសេចក្តីថ្លែងការណ៍អន្តរក្រសួងនោះ។ ជាការឆ្លើយតប ក្រសួង ស.អ.យ. បានចាត់ឱ្យក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) ដើម្បីសម្របសម្រួលជាមួយក្រសួងទាំងបី។

បើទោះបីជាដំណើរការនៃការអនុម័យសេចក្តីថ្លែងការណ៍រួមមិនទាន់បានបញ្ចប់មុនពេលពិធី ដោយសារស្ថានភាពកូវីដ១៩ក៏ដោយ ក៏ក្រសួងទាំងបីឯកភាពគ្នានឹងពិនិត្យមើលសេចក្តីថ្លែងការណ៍នោះ ហើយនឹងស្នើសុំការឯកភាពជាមុនសិនពីនាយករដ្ឋមន្ត្រី ដូចបានបញ្ជាក់នៅក្នុងសុន្ទរកថាបើករបស់ឯ.ឧ. ធូ ស៊ុន នៃក្រសួង ស.អ.យ. ក្នុងពិធីផ្សព្វផ្សាយថ្នាក់ជាតិនេះ។ មុនពិធីផ្សព្វផ្សាយនេះ តំណាងក្រសួងដែលបានចូលរួម ទទួលបានឯកសារពាក់ព័ន្ធនឹងឯការសិក្សាជាសកលនិងពិធីផ្សព្វផ្សាយនេះ រួមទាំងសេចក្តីថ្លែងការណ៍របស់បណ្តាញដែលដឹកនាំដោយកុមារ និងយុវជនផងដែរ។ ការផ្តល់ជូនឯកសារពាក់ព័ន្ធជាមុននេះ គឺដើម្បីឱ្យក្រសួងត្រៀមសុន្ទរកថាបើក និងការឆ្លើយតបទៅនឹងការលើកឡើងរបស់កុមារ។ UNICEF ក៏បានសម្របសម្រួលជាមួយក្រសួងនិងស្ថាប័ននីមួយៗរបស់រដ្ឋាភិបាលដើម្បីធានាឱ្យមានការចូលរួមពីតំណាងរបស់រដ្ឋាភិបាលត្រឹមត្រូវក្នុងពិធីផ្សព្វផ្សាយនេះ។

## ៣. ការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល

ការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល ត្រូវបានដឹកនាំដោយអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា។ បន្ថែមលើការពិគ្រោះយោបល់ជាមួយអង្គការដៃគូដែលបានកំណត់ខាងលើ កិច្ចពិភាក្សាលំអិតក៏បានធ្វើឡើងផងដែរជាមួយសង្គមស៊ីវិលដែលត្រូវបានកំណត់ថាជាអង្គការពាក់ព័ន្ធបំផុតដើម្បីផ្តល់ធាតុចូលនៅក្នុងពិធីផ្សព្វផ្សាយថ្នាក់ជាតិនេះ។ អង្គការទាំងនោះទទួលបានការណែនាំពាក់ព័ន្ធនឹងវិសាលភាពនិងប្រធានបទដែលត្រូវដាក់បញ្ចូលក្នុងបទបង្ហាញរបស់ខ្លួន ដើម្បីឆ្លើយតបនឹងការដកហូតសិទ្ធិសេរីភាពកុមារក្នុងស្ថានភាពមួយចំនួនដូចជា អនីតិជនក្នុងពន្ធនាគារ កុមារតាមម្តាយក្នុងពន្ធនាគារ និងកុមាររស់នៅក្នុងមណ្ឌល។ មានអង្គការមួយដែលមិនអាចចូលរួមបានដោយសារស្ថានភាពកូវីដ១៩ ដូចនេះសង្គមស៊ីវិលដែលបានចូលរួមក្នុងពិធីផ្សព្វផ្សាយនេះមាន អង្គការក្នុងស្រុក This Life Cambodia និងអង្គការអន្តរជាតិ Save the Children ។

លើសពីនេះ ក៏មានសេចក្តីថ្លែងការណ៍រួមជាភាសាខ្មែរ និងអង់គ្លេស របស់សង្គមស៊ីវិលទាក់ទងនឹងការដកហូតសិទ្ធិសេរីភាពកុមារនៅកម្ពុជាផងដែរ ក្នុងគោលបំណងបញ្ជាក់ពីការគាំទ្រនិងការប្តេជ្ញាចិត្តរួមជាធ្លុងមួយដើម្បីធ្វើការទប់ស្កាត់និងឆ្លើយតបទៅនឹងស្ថានភាពទាំងឡាយណាដែលបណ្តាលឱ្យមានការដកហូតសិទ្ធិសេរីភាពកុមារ រួមទាំងការការពារសិទ្ធិនិងសុខុមាលភាពកុមារដែលកំពុងស្ថិតនៅក្នុងស្ថានភាពទាំងនោះ។ មុនពេលពិធីផ្សព្វផ្សាយថ្នាក់ជាតិ សេចក្តីថ្លែងការណ៍រួមនេះត្រូវបានអនុម័តដោយ

សមាជិកទាំងអស់នៃគណៈកម្មាធិការរៀបចំ ពោលគឺអង្គការសង្គមស៊ីវិលចំនួនពីរដែលបានចូលរួមធ្វើបទបង្ហាញក្នុងពិធីនេះ និងក្រុមអង្គការប្រឹក្សាយោបល់ដល់ការសិក្សាជាសកលផងដែរ។ បន្ទាប់ពីពិធីផ្សព្វផ្សាយ សេចក្តីថ្លែងការណ៍នេះក៏ត្រូវបានបញ្ជូនទៅអង្គការក្នុងស្រុកមួយចំនួនដែលពាក់ព័ន្ធនឹងការងារនេះ ដើម្បីស្នើសុំការឯកភាព ហើយកំណែចុងក្រោយនៃសេចក្តីថ្លែងការណ៍នេះ ត្រូវបានផ្សព្វផ្សាយនៅថ្ងៃទី៥ ឧសភា ឆ្នាំ២០២១។ សេចក្តីថ្លែងការណ៍ទាំងស្រុងមាននៅក្នុងឧបសម្ពន្ធ ហើយក៏មានផងដែរនៅក្នុងតំណភ្ជាប់នេះ http://bit.ly/GSCDLCambodiaCivilSociety Statement ។

## ៤. ផែនការរៀបចំកិច្ចប្រជុំត្រៀមសម្រាប់សន្និសីទពិភពលោក ២០២១

ផែនការរៀបចំកិច្ចប្រជុំត្រៀមសម្រាប់សន្និសីទពិភពលោក២០២១ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានដឹកនាំដោយអង្គការ Terre des hommes ក្នុងនាមអង្គការផ្តួចផ្តើមគំនិតជាសកលស្តីពីយុត្តិធម៌អនីតិជន និងអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា។ លិខិតអញ្ជើញចូលរួមប្រជុំចង្អៀតនេះត្រូវបានផ្ញើជូនអង្គការនិងស្ថាប័នដែលធ្វើការក្នុងវិស័យយុត្តិធម៌អនីតិជន ហើយការចូលរួមមិនត្រូវបានបើកទូលាយទេ ដោយសារពាក់ព័ន្ធនឹងបច្ចេកទេសនៃកិច្ចប្រជុំ។ ការស្ទង់មតិមុនកិច្ចប្រជុំត្រូវបានរៀបចំឡើងដើម្បីកំណត់បញ្ហាប្រឈមចម្បងៗនិងអាទិភាពទាក់ទងនឹងវិស័យយុត្តិធម៌អនីតិជននៅកម្ពុជា ហើយលទ្ធផលនៃការស្ទង់មតិនេះត្រូវបានបង្ហាញក្នុងកិច្ចប្រជុំផងដែរ។ អង្គការដៃគូមួយចំនួនត្រូវបានទាក់ទងឱ្យធ្វើបទបង្ហាញ៥នាទីម្នាក់ស្តីពីការងាររបស់ខ្លួនដែលទាក់ទងនឹងវិស័យយុត្តិធម៌អនីតិជននៅកម្ពុជា។

## ៥. ការរៀបចំកិច្ចការរដ្ឋបាល

សមាជិកទាំងអស់នៃគណៈកម្មាធិការរៀបចំ បានគាំទ្រដល់គំនិតផ្តួចផ្តើមក្នុងការរៀបចំផែនការនិងសកម្មភាពជាយុទ្ធសាស្ត្រ ដែលបានប្រព្រឹត្តទៅអស់រយៈពេលជាច្រើនខែ។ ការរៀបចំកិច្ចការរដ្ឋបាលរួមមាន ការរៀបចំផែនការសកម្មភាព ការកែសម្រួលរបៀបវារៈ ការជ្រើសរើសអ្នកពាក់ព័ន្ធនៅថ្នាក់ក្រោម ការរៀបចំការណែនាំអំពីសម្ភារៈ និងបច្ចេកទេស ការងារចាត់ចែងលើការចុះឈ្មោះនិងលិខិតអញ្ជើញ ការបកប្រែឯកសារ ការបង្កើតនិងការអនុវត្តយុទ្ធសាស្ត្រទាក់ទងនឹងស្លាកសញ្ញានិងការផ្តល់ព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។ ការជ្រើសរើសអ្នកចូលរួមត្រូវបានធ្វើឡើងជាលក្ខណៈយុទ្ធសាស្ត្រ ដោយពិចារណាលើទិដ្ឋភាពជាទូទៅដែលទាក់ទងនឹងការងារដកហូតសិទ្ធិសេរីភាពកុមារ ដោយរួមមានភាគីខាងរដ្ឋាភិបាល សង្គមស៊ីវិល ភ្នាក់ងារអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានសិក្សា ការិយាល័យមេធាវី អ្នកប្រកបវិជ្ជាជីវៈច្បាប់ អ្នកជំនាញឯករាជ្យ និង សារព័ត៌មាន។ កុមារនិងយុវជនត្រូវបានអញ្ជើញចូលរួមដោយអង្គការបណ្តាញដឹកនាំដោយយុវជននិងកុមារ ដោយមានទាំងសមាជិកមួយចំនួននៃស្ថាប័នសាធារណៈនៅកម្ពុជានិងក្រៅប្រទេសដែលបានដឹងឮតាមរយៈការផ្សព្វផ្សាយផ្ទាំងសារព័ត៌មានយ៉ាងទូលំទូលាយ។

បន្ថែមលើនេះ សាកលវិទ្យាល័យសិទ្ធិមនុស្សបានរៀបចំបទបង្ហាញស្តីពីការសិក្សាជាសកល និងជួយសម្របសម្រួលក្នុងការអញ្ជើញអ្នកតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកអំពើហិង្សាលើកុមារ ឱ្យថ្លែងចំណាប់អារម្មណ៍បើកក្នុងពិធីផ្សព្វផ្សាយនេះ។ រីឯ UNICEF បានថ្លែងសន្ទរកថាបិទ។

ការងាររៀបចំលំអិតទាក់ទងនឹងពិធីផ្សព្វផ្សាយនេះ គឺមាននៅក្នុងឯកសារដាច់ដោយឡែកមួយដែលផ្តោតលើបទពិសោធន៍រៀបចំពិធីនេះនៅកម្ពុជា ដើម្បីជាជំនួយដល់ការរៀបចំនៅក្នុងប្រទេសផ្សេងទៀត។

# ៥ សេចក្តីសង្ខេបស្តីពីពិធីផ្សព្វផ្សាយថ្នាក់ជាតិ

**ពិធីនេះក៏ត្រូវបានថតទុកជាឯកសារដែលអាចស្តាប់បានតាមរយៈតំណភ្ជាប់នេះ http://bit.ly/GSCDLCambodiaRecording, ដែលទាំងសំឡេងដើមជាភាសាខ្មែរនិងអង់គ្លេស។ ចំណែកឯការបកប្រែពីភាសាអង់គ្លេសទៅភាសាខ្មែរវិញ គឺមាននៅក្នុងសំណេរលំអិតនៃវីដេអូ។ ឯកសារបទបង្ហាញនៅក្នុងពិធីនេះ មាននៅក្នុងតំណភ្ជាប់នេះ http://bit.ly/GSCDLCambodiaPPT រីឯរបាយការណ៍លទ្ធផលស្តីពីពិធីនេះ គឺមាននៅក្នុងតំណភ្ជាប់នេះ http://bit.ly/GSCDLCambodiaReport ។**

**ប្អូន បញ្ញា** ដែលជាអ្នកតំណាងកុមារនៃបណ្តាញដឹកនាំដោយកុមារនិងយុវជន គឺជាអ្នកកាន់កម្មវិធីនៃពិធីផ្សព្វផ្សាយនេះ។

## ១. ចំណាប់អារម្មណ៍បើក

ចំណាប់អារម្មណ៍បើកត្រូវបានថ្លែងដោយ**លោកស្រីបណ្ឌិត Najat Maalla M’jid អ្នកតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកអំពើហិង្សាលើកុមារ។** នៅក្នុងចំណាប់អារម្មណ៍បើកនោះ លោកស្រីបានកោតសរសើរដល់ការជួបជុំស្ថាប័នសំខាន់ៗ ដែលនឹងអនុញ្ញាតឱ្យមានកិច្ចសហការរឹងមាំនិងប្រកបដោយប្រសិទ្ធភាពក្នុងការអនុវត្តអនុសាសន៍នៃការសិក្សាជាសកលនៅកម្ពុជា។ ដោយបញ្ជាក់យ៉ាងច្បាស់ថា ការដកហូតសិទ្ធិសេរីភាព គឺជាការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិជាមូលដ្ឋានរបស់កុមារ លោកស្រីបានកត់សម្គាល់ថា ការមិនយកចិត្តទុកដាក់លើកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាព ធ្វើឱ្យប៉ះពាល់ដល់សមិទ្ធិផលនៃរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។ លោកស្រីបានគូសបញ្ជាក់ថា ការឃុំខ្លួនត្រូវតែអនុវត្តជាវិធានការចុងក្រោយសម្រាប់កុមារ ក្នុងកាលៈទេសៈចាំបាច់បំផុត និងក្នុងរយៈពេលខ្លីបំផុតតាមដែលអាចធ្វើទៅបាន ហើយថាជម្រើសផ្សេងក្រៅពីការឃុំខ្លួនត្រូវផ្តល់ជាអាទិភាពខ្ពស់បំផុត។ លោកស្រីក៏បានកោតសរសើរផងដែរដល់រាជរដ្ឋាភិបាលកម្ពុជាដែលសម្រេចបាននូវវឌ្ឍនៈភាពពាក់ព័ន្ធនឹងការការពារសិទ្ធិកុមារ ជាពិសេសក្នុងវិស័យយុត្តិធម៌អនីតិជន និងកិច្ចការពារកុមារ។ លោកស្រីបានលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាលប្រែក្លាយការប្តេជ្ញាចិត្តរបស់ខ្លួនទៅជាសកម្មភាពដើម្បីទប់ស្កាត់និងបញ្ចប់ការដកហូតសិទ្ធិសេរីភាពគ្រប់ទម្រង់លើកុមារ។ លោកស្រីក៏បានអបអរសាទរដល់កុមារទាំងអស់ដែលបានចូលរួមក្នុងដំណើរការនេះ ហើយលើកទឹកចិត្តឱ្យស្ថាប័នពាក់ព័ន្ធបន្តអនុញ្ញាតឱ្យកុមារចូលរួមក្នុងដំណើរការធ្វើការសម្រេចចិត្ត។ ជាចុងក្រោយ លោកស្រីបានសម្តែងនូវសេចក្តីសង្ឃឹមថា «ពិធីផ្សព្វផ្សាយនេះនឹងក្លាយជាចំណុចចាប់ផ្តើមក្នុងការបញ្ចប់ភាពងាយរងគ្រោះ ការមាក់ងាយ និងការមិនយកចិត្តទុកដាក់ពីសង្គមទៅលើកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាពនៅកម្ពុជា»។ ឯកសារវីដេអូស្តីពីការថ្លែងចំណាប់អារម្មណ៍បើកអាចទស្សនាបាននៅក្នុងតំណភ្ជាប់នេះ http://bit.ly/GSCDLCambodiaSRSG-VAC.

## ២. សុន្ទរកថាបើក

សុន្ទរកថាបើក ត្រូវបានថ្លែងដោយ**ឯ.ឧ. ធូ ស៊ុន រដ្ឋលេខាធិការនៃក្រសួង ស.អ.យ.**។ នៅក្នុងសុន្ទរកថាបើក ឯកឧត្តម បានបញ្ជាក់ពីការទទួលបានសេចក្តីសង្ខេបលទ្ធផលនៃការសិក្សាជាសកលជាភាសាខ្មែរ ដែលរួមមានអនុសាសន៍សម្រាប់រដ្ឋជាសមាជិក សេចក្តីព្រាងនៃសេចក្តីថ្លែងការណ៍រួមសម្រាប់ជាការពិចារណាដោយក្រសួងទាំងបី ដែលបានផ្ញើដោយអ្នកជំនាញឯករាជ្យក្នុងនាមគណៈកម្មាធិការរៀបចំ។ ឯកឧត្តម ក៏បានពន្យល់ដែរថាបានទទួលសំណើពី UNICEF ឱ្យក្រសួងដឹកនាំដំណើរការពិនិត្យនិងសម្រេចដោយសម្របសម្រួលជាមួយក្រសួង ម.ផ. និងក្រសួង ក.យ. ហើយថាឥឡូវនេះក្រសួងបានចាត់ឱ្យ ក.ជ.ក ពិនិត្យមើលសេចក្តីព្រាងនោះដើម្បីឱ្យមានសេចក្តីគ្រប់ជ្រុងជ្រោយនិងស្របតាមស្ថានភាពកម្ពុជា។ ឯកឧត្តម បានគូសបញ្ជាក់ថា ក្រសួងទាំងបីឯកភាពគ្នានឹងស្នើសុំការយល់ព្រមពីនាយករដ្ឋមន្ត្រីជាមុនដើម្បីទទួលបានការគាំទ្រពេញលេញពីរាជរដ្ឋាភិបាល ដែលនឹងជួយដល់ការអនុវត្តការប្តេជ្ញាចិត្តនៅក្នុងសេចក្តីថ្លែងការណ៍នោះប្រកបដោយប្រសិទ្ធភាព។

ឯកឧត្តម ក៏បានពន្យល់ផងដែរថា ក្រសួងពាក់ព័ន្ធទាំងបីបានខិតខំកែលំអស្ថានភាពកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាពនៅកម្ពុជា ដោយរួមមានអនីតិជនទំនាស់នឹងច្បាប់ កុមាររស់នៅជាមួយម្តាយក្នុងពន្ធនាគារ និងកុមាររស់នៅក្នុងមណ្ឌល។ ឯកឧត្តម បានបញ្ជាក់ថា ច្បាប់ស្តីពីយុត្តិធម៌អនីតិជនគឺជាមូលដ្ឋានគ្រឹះក្នុងការកាត់បន្ថយចំនួនអនីតិជនទំនាស់នឹងច្បាប់ ហើយថាក្រសួងពាក់ព័ន្ធកំពុងសហការគ្នាដើម្បីកាត់បន្ថយភាពកកស្ទះនៅក្នុងពន្ធនាគារតាមរយៈការអនុវត្តវិធានការផ្សេងក្រៅពីការឃុំខ្លួនដែលមានដូចជាការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជាដើម។ ឯកឧត្តម ក៏បានបន្ថែមថា ក្រសួងទាំងបីនឹងពង្រឹងកិច្ចសហការដើម្បីធានាឱ្យមានការពិចារណាខ្ពស់លើឧត្តមប្រយោជន៍កុមារសម្រាប់សំណុំរឿងពាក់ព័ន្ធនឹងជនសង្ស័យជាស្ត្រីដែលមានកូនតូច ហើយកែលំអស្ថានភាពរស់នៅរបស់កុមារតាមម្តាយក្នុងពន្ធនាគារ។

ទាក់ទងនឹងកុមាររស់នៅក្នុងមណ្ឌល ឯកឧត្តមបានគូសបញ្ជាក់ថា ក្រសួង ស.អ.យ បានប្រឹងប្រែងខ្លាំងណាស់ដើម្បីកាត់បន្ថយចំនួនមណ្ឌលនិងចំនួនកុមាររស់នៅក្នុងមណ្ឌល តាមរយៈកម្មវិធីសមាហរណកម្ម។ ឯកឧត្តម បានពន្យល់បន្ថែមថា បច្ចុប្បន្នក្រសួង ស.អ.យ កំពុងដឹកនាំធ្វើសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារដែលផ្តោតលើបញ្ហានានាដែលកុមារងាយរងគ្រោះប្រឈម។

## ៣. លទ្ធផលសំខាន់ៗនៃការសិក្សាជាសកល

លទ្ធផលសំខាន់ៗនៃការសិក្សាជាសកលត្រូវបានបង្ហាញជូនដោយ **លោកសាស្ត្រាចារ្យ Manfred Nowak** អ្នកជំនាញឯករាជ្យដែលបានដឹកនាំការសិក្សាជាសកលនេះ និងជាអគ្គលេខាធិការនៃសាកលវិទ្យាល័យសិទ្ធិមនុស្ស។ លោកសាស្ត្រាចារ្យ បានចាប់ផ្តើមដោយសង្ខេបសារតារួមទាំងរយៈពេលនៃការសិក្សាជាសកល និងបានពន្យល់ថា ការសិក្សាជាសកលនេះចាំបាច់ខ្លាំងណាស់ ពីព្រោះថាបើទោះបីជាមានការការពារដែលត្រូវបានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារក៏ដោយ ក៏នៅតែមានកុមារជាច្រើនត្រូវបានដកហូតសិទ្ធិសេរីភាព ហើយថាពុំទាន់មានទិន្នន័យគួរជាទីទុកចិត្តនៅឡើយទេ។ លោកបានពន្យល់ថា ការសិក្សាជាសកលនេះសម្រេចទៅបានដោយសារមានការខិតខំរួមគ្នារវាងរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការសង្គមស៊ីវិល ក្រុមអ្នកស្រាវជ្រាវ គ្រឹះស្ថានសិក្សា និងការចូលរួមពីកុមារផងដែរ។

លោកបានពន្យល់ថា ការសិក្សាជាសកលនេះគ្របដណ្តប់ផ្នែកពាក់ព័ន្ធចំនួន៦៖

១. កុមារដែលត្រូវដកហូតសិទ្ធិសេរីភាពក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឬអនីតិជនទំនាស់នឹងច្បាប់
២. កុមាររស់នៅក្នុងពន្ធនាគារជាមួយម្តាយ
៣. កុមារដែលត្រូវដកហូតសិទ្ធិសេរីភាពដោយហេតុផលអន្តោប្រវេសន៍
៤. កុមារដែលត្រូវដកហូតសិទ្ធិសេរីភាពនៅក្នុងមណ្ឌលថែទាំ
៥. កុមារដែលត្រូវដកហូតសិទ្ធិសេរីភាពក្នុងស្ថានភាពជម្លោះប្រដាប់អាវុធ និង
៦. កុមារដែលត្រូវដកហូតសិទ្ធិសេរីភាពដោយហេតុផលសន្តិសុខជាតិ។

# ៥ សេចក្តីសង្ខេបស្តីពីពិធីផ្សព្វផ្សាយថ្នាក់ជាតិ

លោកបានគូសបញ្ជាក់ថា ការសិក្សាជាសកលបានរកឃើញថាមានកុមារជាង៧.២លាននាក់ដែលកំពុងត្រូវបានដកហូតសិទ្ធិសេរីភាពជារៀងរាល់ឆ្នាំ។ លោកបានបន្តពន្យល់ពីស្ថានភាពរបស់កុមារក្នុងផ្នែកនីមួយៗខាងលើដោយភ្ជាប់ជាមួយនឹងអនុសាសន៍តាមផ្នែកនីមួយៗនោះ ដែលក្នុងនោះមានដូចជាការអនុម័តគោលនយោបាយគ្រប់ជ្រុងជ្រោយសម្រាប់ការធ្វើសមាហរណកម្មកុមារចេញពីមណ្ឌល ការអនុវត្តវិធានការផ្សេងក្រៅពីការដាក់ក្នុងមណ្ឌល ការអនុវត្តវិធានការបង្វែរ ការមិនដាក់ទោសទណ្ឌលើអាកប្បកិរិយារបស់កុមារ ការពង្រឹងសមត្ថភាពមន្ត្រីយុត្តិធម៌ និងបង្ការការឃុំខ្លួនទាក់ទងនឹងអន្តោប្រវេសន៍។ ដោយគូសបញ្ជាក់ពីអនុសាសន៍សំខាន់ៗ លោកបានមានប្រសាសន៍សង្កត់ធ្ងន់លើតម្រូវការក្នុងការកាត់បន្ថយចំនួនកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាព និងធានាថាការឃុំខ្លួនត្រូវតែអនុវត្តជាជម្រើសចុងក្រោយ និងមានរយៈពេលខ្លីបំផុត។

បន្ទាប់មក លោកបានជម្រាបជូនពីការងារតាមដានមួយចំនួនដែលផ្តួចផ្តើមដោយសាកលវិទ្យាល័យសិទ្ធិមនុស្ស រួមមានដូចជាការរៀបចំផ្សព្វផ្សាយថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ នៅជុំវិញពិភពលោក ការបកប្រែលទ្ធផលសង្ខេបនៃការសិក្សាជាសកលនេះទៅជាភាសាដែលប្រើប្រាស់ដោយអង្គការសហប្រជាជាតិ ការបង្កើតឯកសារណែនាំវគ្គសិក្សាតាមប្រព័ន្ធអនឡាញ និងការផលិតឯកសារជាវីដេអូបែបកុមារមេត្រីស្តីពីការសិក្សាជាសកលនេះ រួមទាំងការសិក្សាស្រាវជ្រាវស៊ីជម្រៅតាមរយៈបណ្តាញគ្រឹះស្ថានសិក្សា។

ឆ្លើយតបទៅនឹងសំណួរថាតើការសិក្សាជាសកលនេះបានសិក្សាដែរឬទេពីឫសគល់នៃបញ្ហាដែលនាំឱ្យមានការដកហូតសិទ្ធិសេរីភាពកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ អ្នកជំនាញឯករាជ្យបានឆ្លើយថាការសិក្សាជាសកលនេះបានពិនិត្យមើលយ៉ាងដិតដល់ពីឫសគល់នៃបញ្ហាទាំងនោះ រួមមានដូចជាគោលនយោបាយតឹងរឹងពេកស្តីពីបទល្មើស គោលនយោបាយរឹតបន្តឹងលើអន្តោប្រវេសន៍ ការខ្វះខាតការគាំទ្រដល់គ្រួសារ និងប្រព័ន្ធសុខុមាលភាពកុមារជាដើម។

ឆ្លើយតបទៅនឹងសំណួរពាក់ព័ន្ធនឹងអនុសាសន៍សម្រាប់កុមារតាមម្តាយក្នុងពន្ធនាគារ លោកបានឆ្លើយថា ជម្រើសផ្សេងក្រៅពីការឃុំខ្លួន ដូចជាដាក់ឃុំនៅផ្ទះ និងវិធានការដោះស្រាយក្រៅនីតិវិធីតុលាការ គួរយកមកពិចារណាដោយមន្ត្រីយុត្តិធម៌។ សំណួរមួយទៀតសួរថាតើមណ្ឌលប្រភេទណា ឬស្ថានភាពកុមារនៅក្នុងមណ្ឌលប្រភេទណាដែលចាត់ទុកថាជាការដកហូតសិទ្ធិសេរីភាព តបនឹងសំណួរនេះលោកបានឆ្លើយថា បើទោះបីជាមានការលំបាកក្នុងបែងចែកឱ្យបានច្បាស់លាស់ក៏ដោយ ក៏យើងអាចដឹងតាមរយៈការសួរសំណួរសំខាន់មួយថា តើកុមាររស់នៅក្នុងមណ្ឌលទាំងនោះអាចចាកចេញពីមណ្ឌលតាមបំណងរបស់ខ្លួនដែរឬទេ?។ ដើម្បីយល់ឱ្យកាន់តែច្បាស់ពីចំណុចនេះ ចាំបាច់ត្រូវអានជំពូកពាក់ព័ន្ធនៃការសិក្សាជាសកល។

ឆ្លើយតបនឹងសំណួរចុងក្រោយថាតើឯកសារដែលរៀបចំឡើងបែបកុមារមេត្រី មានហើយឬនៅ **លោក Manu Krishan** អ្នកគ្រប់គ្រងការសិក្សាជាសកល នៅសាកលវិទ្យាល័យសិទ្ធិមនុស្ស បានឆ្លើយថា នាយកដ្ឋានផ្នែកសិក្សាតាមប្រព័ន្ធអនឡាញ កំពុងតែធ្វើការលើរឿងនេះយ៉ាងជិតស្និទ្ធជាមួយអង្គការ Terre des homes និង អង្គការ CODA ដើម្បីផលិតឯកសារនេះជាមួយនឹងឯកសារសង្ខេបបែបកុមារមេត្រីដែលឥឡូវនេះកំពុងត្រូវបានពិនិត្យកែសម្រួលចុងក្រោយដោយក្រុមការងារផ្នែកកិច្ចការចូលរួមរបស់កុមារនៃការសិក្សាជាសកលនេះ។ ឯកសារទាំងនេះនឹងដាក់នៅក្នុងគេហទំព័រខាងក្រោមនៅពេលដែលរួចរាល់។

ព័ត៌មានលំអិតមាននៅក្នុងបទបង្ហាញ ហើយឯកសារវីដេអូលំអិតដែលពន្យល់ពីការសិក្សាជាសកល មាននៅក្នុងតំណភ្ជាប់នេះ http://bit.ly/GSCDLPresentation ។ លទ្ធផលពេញលេញនៃការសិក្សាជាសកល និងសេចក្តីសង្ខេបជាភាសាផ្សេងៗ មាននៅក្នុងតំណភ្ជាប់នេះ https://omnibook.com/Global-Study-2019 ឬ https://nochildbehindbars.com[៣]

---

៣ គេហទំព័រនេះត្រូវបានផ្សព្វផ្សាយថ្មីៗនេះដោយសាកលវិទ្យាល័យសិទ្ធិមនុស្ស ដោយមានព័ត៌មានជាច្រើនពាក់ព័ន្ធនឹងកិច្ចការសាកលវិទ្យាល័យដែលគាំទ្រដល់ការសិក្សាជាសកល មានទាំងគំរោងបច្ចុប្បន្នដែលគាំទ្រដល់ការអនុវត្តអនុសាសន៍នៃការសិក្សាជាសកល និងព័ត៌មានស្តីពីព្រឹត្តិការណ៍ផ្សេងៗដែលក្រុមការងារនៃការសិក្សាជាសកលបានចូលរួម។ ព័ត៌មានលំអិតស្តីពីការសិក្សាជាសកលអាចត្រូវបានផ្តល់ជូនបានតាមរយៈវគ្គសិក្សាអនឡាញដោយឥតគិតថ្លៃដែលរៀបចំដោយសាកលវិទ្យាល័យសិទ្ធិមនុស្ស https://gchumanrights.org/education/e-learning/moocs/children-deprived-of-liberty-learning-from-the-un-global-study/about.html.

## ៤. សំឡេងសង្គមស៊ីវិល

**លោក ឈិន សែ អនុប្រធានអង្គការ This Life Cambodia** បានផ្តល់បទបង្ហាញមុនគេស្តីពីការសិក្សាស្រាវជ្រាវចំនួនពីរទាក់ទងនឹងអនីតិជនទំនាស់នឹងច្បាប់ និង កុមាររស់នៅក្នុងពន្ធនាគារជាមួយម្តាយ។ ការស្រាវជ្រាវទីមួយ មានចំណងជើងថា «មិនមានទីកន្លែងសម្រាប់កុមារ៖ ជម្រើសផ្សេងក្រៅពីការឃុំខ្លួនកុមារនៅកម្ពុជា» ត្រូវបានបញ្ចប់នៅដើមឆ្នាំ២០២១។ លោកបានពន្យល់ថា បើទោះបីជាច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលចូលជាធរមានកាលពីដើមឆ្នាំ២០១៧ បានបញ្ញត្តិថាការឃុំខ្លួនគឺជាជម្រើសចុងក្រោយក៏ដោយ ក៏ចំនួនអនីតិជននៅពន្ធនាគារមានការកើនឡើងជិតបីដងរយៈពេលបីឆ្នាំជាប់គ្នា ដោយសារតែការប្រើប្រាស់គ្រឿងញៀននៅតំបន់ជាយក្រុងនិងជនបទ។ លោកបានពន្យល់ថាអនីតិជនភាគច្រើនដែលត្រូវបានផ្តន្ទាទោស គឺពាក់ព័ន្ធនឹងបទល្មើសអហិង្សា។ អនីតិជនចំនួន៦៥%ដែលអង្គការ This Life Cambodia បានសម្ភាស បង្ហាញថាការប្រើប្រាស់គ្រឿងញៀនបាននាំឱ្យពួកគេប្រព្រឹត្តបទល្មើស។

លោកបានពន្យល់ថា ប្រជាពលរដ្ឋភាគច្រើននៅក្នុងសហគមន៍ដែលត្រូវបានសម្ភាស គិតថាពន្ធនាគារជាកន្លែងមិនល្អទេសម្រាប់អនីតិជន ហើយថាអនីតិជនគួរទទួលបានការអប់រំត្រឹមត្រូវជាជាងចំណាយពេលនៅក្នុងពន្ធនាគារ។ ការសម្ភាសន៍ជាមួយអាជ្ញាធរ ក៏បានបង្ហាញដែរថា អាជ្ញាធរសង្ឃឹមថានឹងឃើញការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងវិធានការបង្វែរឱ្យបានល្អ។ លោកបានសន្និដ្ឋានថា វិធានការបង្វែរអាចចំណាយថវិកាច្រើនក្នុងរយៈពេលខ្លី ប៉ុន្តែវិធានការនេះផ្តល់លទ្ធផលវិជ្ជមានរយៈពេលវែង ហើយថា វិធានការនេះគួរត្រូវបានយកមកពិចារណាសម្រាប់ជាឧត្តមប្រយោជន៍របស់កុមារ។

អ្នកចូលរួមម្នាក់ពីឧត្តមស្នងការអង្គការសហប្រជាជាតិដើម្បីសិទ្ធិមនុស្ស (OHCHR) បានឯកភាពទៅនឹងក្រាហ្វិកដែលបង្ហាញថាមានអនីតិជនជាច្រើននៅកម្ពុជាដែលត្រូវបានជាប់ឃុំបណ្តោះអាសន្នរង់ចាំការកាត់ទោស ដោយសារបទល្មើសមជ្ឈឹម ដូចជា បទលួចតូចតាច ហើយលោកបានស្នើថា តុលាការគួរជៀសវាងឃុំខ្លួនអនីតិជនរង់ចាំការជំនុំជម្រះសម្រាប់បទល្មើសមជ្ឈឹម ឬបទល្មើសដែលមិនបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សង្គម។

បន្ទាប់មក លោកអនុប្រធានបាននិយាយអំពីការសិក្សាស្រាវជ្រាវក្នុងឆ្នាំ២០១៩ ស្តីពី «ហេតុអ្វីកុមារតាមម្តាយចូលពន្ធនាគារ៖ កត្តាសំខាន់ដែលនាំឱ្យមានការសម្រេចចិត្តបែបនេះនៅកម្ពុជា»។ គាត់បានពន្យល់ថា មានកត្តាមួយចំនួនដូចជា ការរើសអើង ភាពក្រីក្រ មិនមានអ្នកថែទាំ គ្មានឱកាសទទួលការសិក្សា និង អាយុរបស់កុមារដែលច្បាប់អនុញ្ញាតឱ្យនៅជាមួយម្តាយដល់អាយុបីឆ្នាំ។ ដូចនេះ លោកបានទទូចស្នើឱ្យអាជ្ញាធរអនុវត្តជម្រើសផ្សេងក្រៅពីការឃុំខ្លួនសម្រាប់ម្តាយដែលមានកូនតូច ផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ម្តាយធ្វើការសម្រេចចិត្តទាក់ទងនឹងកូនតូចរបស់ខ្លួន ឱ្យពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ដើម្បីយល់ច្បាស់ពីតម្រូវការជាក់លាក់របស់កុមារតាមម្តាយក្នុងពន្ធនាគារ និងឱ្យបង្កើតទីកន្លែងបែបកុមារមេត្រី និងសេវាក្នុងពន្ធនាគារសម្រប់កុមារទាំងនេះ។

លោកបានពន្យល់ថា អង្គការ This Life Cambodia បានជួយគាំទ្រដល់អនីតិជនទំនាស់នឹងច្បាប់តាំងពីឆ្នាំ២០១០នៅក្នុងខេត្តចំនួនបី ហើយថាអង្គការនេះក៏ជួយគាំទ្រផងដែរដល់ស្ត្រីជាម្តាយ ដោយផ្តល់សេវារយៈពេលខ្លីមុនពេលជាប់ឃុំ ដើម្បីស្វែងរកជម្រើសនានាឱ្យមានការរស់នៅជាមួយគ្រួសារ ក៏ដូចជាការផ្តល់ការគាំទ្ររយៈពេលវែងក្នុងពេលជាប់ឃុំដើម្បីជួយកុមារឱ្យបន្តការសិក្សានិងរក្សាទំនាក់ទំនងជាមួយម្តាយ។

ព័ត៌មានទាក់ទងនឹងការសិក្សាស្រាវជ្រាវទាំងពីរនេះ របាយការណ៍និងកម្មវិធីផ្សេងៗរបស់ This Life Cambodia មាននៅក្នុងតំណភ្ជាប់នេះ៖ https://thislife.ngo/research។

បទបង្ហាញទី២ ត្រូវបានផ្តល់ជូនដោយ **លោក លាង ឡូ ប្រធានផ្នែកកិច្ចការពារកុមារនៃអង្គការ Save the Children** ដែលបាននិយាយអំពីកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាពនៅក្នុងមណ្ឌល។ លោកបានចាប់ផ្តើម ដោយពន្យល់ថា ដោយសារតែមានកិច្ចខិតខំប្រឹងប្រែង និងសហការគ្នាល្អរវាងក្រសង្វង ស.អ.យ. អង្គការសង្គមស៊ីវិល និង UNICEF ចំនួនមណ្ឌលថែទាំជំនួសបានថយចុះ៤៣% ពោលគឺធ្លាក់ចុះពី ៤០៦ ក្នុងឆ្នាំ២០១៥ មកត្រឹម ២៣២ ក្នុងឆ្នាំ ២០១៩ រីឯចំនួនកុមារក្នុងមណ្ឌលវិញថយចុះ៥៩% គឺថយចុះពី ១៦,៥៧៩ ក្នុងឆ្នាំ២០១៥ មកនៅត្រឹម ៦,៧៧៨ ក្នុងឆ្នាំ ២០១៩។ លោកបានពន្យល់ទៀតថា កុមារប្រមាណ ៨០% នៅក្នុងមណ្ឌល យ៉ាងហោចណាស់ក៏មាន ឪពុក ឬម្តាយម្នាក់ដែរដែលនៅរស់ ហើយថាកត្តាចម្បងដែលនាំឱ្យមានការបំបែកកុមារចេញពីគ្រួសារ រួមមាន ភាពក្រីក្រ គ្រួសារធ្លាក់ខ្លួន

ឈឺ និងការបោះបង់កុមារចោលជាដើម។ កុមារាភាគតិចណាស់ដែលត្រូវបានគេបញ្ជូន ទៅរស់នៅក្នុងមណ្ឌលដោយសារតែពួកគេគិតថាកូនស្រីងាយស្រួលមើលថែនិងអាចជួយកិច្ចការផ្ទះបាន ចំណែកកូនប្រុសវិញជាធម្មតាត្រូវបានគេបញ្ជូនទៅរស់នៅក្នុងមណ្ឌលដោយសារតែពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ បញ្ហាអាកប្បកិរិយាដូចជាការផឹកស្រា និងប្រើប្រាស់គ្រឿងញៀនជាដើម។

លោកបានពន្យល់ថា ឪពុកម្តាយគិតថាទទួលបានផលប្រយោជន៍នៅពេលដាក់កូននៅក្នុងមណ្ឌល ដូចជាទទួលបានការមើលថែទាំ ការអប់រំ កាត់បន្ថយការចំណាយក្នុងគ្រួសារ អាចរស់នៅក្នុងបរិយាកាសសុវត្ថិភាព និង ផលប្រយោជន៍ផ្សេងទៀត។ អ្នកចូលរួមម្នាក់បានសំដែងការមិនសប្បាយចិត្តចំពោះឪពុកម្តាយមួយចំនួនដែលគិតថាកូនរបស់ខ្លួនជាបន្ទុក ហើយបញ្ជូនកូនទៅរស់នៅក្នុងមណ្ឌលដោយសារតែហេតុផលនេះ ហើយជំរុញឱ្យឪពុកម្តាយទាំងនោះគិតឱ្យបានមត់ចត់មុននឹងសម្រេចបែបនេះ។

បន្ទាប់មក លោកប្រធានផ្នែកកិច្ចការពារកុមារបានលើកឡើងពីកំណែទម្រង់ផ្នែកច្បាប់ក្នុងផ្នែកកិច្ចការពារកុមារក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ ដោយយល់ពីសារៈសំខាន់ក្នុងការមើលថែកុមារជាលក្ខណៈគ្រួសារ រាជរដ្ឋាភិបាល បានចាត់ទុកការទុកដាក់កុមារក្នុងមណ្ឌលគឺជាជម្រើសចុងក្រោយ ហើយបានផ្តល់ការណែនាំពីទម្រង់ផ្សេងៗនៃការថែទាំជំនួស។ ដើម្បីគាំទ្រដល់ការងារនេះ លោកបានពន្យល់ថា កម្មវិធី Family Care First (FCF) | REACT គឺជាបណ្តាញដ៏ធំមួយដែលដឹកនាំដោយក្រសួង ស.អ.យ. និងសម្របសម្រួលដោយអង្គការ Save the Children ដែលមានទំនាក់ទំនងការងារជាមួយសមាជិកជាង ៦០អង្គការ ដើម្បីគាំទ្រដល់កុមារកម្ពុជាឱ្យរស់នៅដោយមានការថែទាំជាលក្ខណៈគ្រួសារប្រកបដោយសុវត្ថិភាព។ ផ្អែកលើរបាយការណ៍ចុងក្រោយបានបង្ហាញថាមានការគ្រប់គ្រងករណីកុមារចំនួន ២,២៥០នាក់ និងមានអ្នកទទួលបានផលប្រយោជន៍ពីការផ្តល់សេវារហូតដល់ទៅ ១៨,៧២០នាក់ ដែលក្នុងនោះមានកុមារចំនួន ៣៤៣នាក់ត្រូវបានធ្វើសមាហរណកម្មទៅក្នុងគ្រួសាររបស់ខ្លួនវិញ កុមារ ១៥៣នាក់ ដាក់ឱ្យរស់នៅជាមួយសាច់ញាតិ និងកុមារ១២៣នាក់ដាក់ឱ្យរស់នៅជាមួយគ្រួសារធម៌។ លើសពីនេះទៀត មណ្ឌលថែទាំជំនួសចំនួន១៧ កំពុងស្ថិតក្នុងដំណើរការនីតិវិធីបិទ។

លោកបានពន្យល់ថា Save the Children បានធ្វើកិច្ចសន្យាបន្តជាមួយដៃគូអនុវត្តការងារនេះ ពង្រឹងសមត្ថភាពដៃគូរបស់ខ្លួន និងកម្លាំងសេវាសង្គម ចែករំលែកចំណេះដឹងដល់ដៃគូ សម្របសម្រួលការងារជាមួយក្រសួង ស.អ.យ. និងស្ថាប័នផ្សេងទៀត។ លោកបានស្នើឱ្យពន្លឿនការងាររៀបចំសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ គោលនយោបាយសំខាន់ៗនិងឯកសារណែនាំពាក់ព័ន្ធនឹងការថែទាំដោយសាច់ញាតិនិងគ្រួសារធម៌ ការអនុវត្តកម្មវិធីបណ្តុះបណ្តាលស្តីពីកម្លាំងសេវាសង្គម និងការបញ្ចប់ផែនការកិច្ចការពារកុមារនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ព័ត៌មានបន្ថែមស្តីពីកម្មវិធី FCF | REACT និងការអនុវត្តកម្មវិធី គឺមាននៅក្នុងតំណភ្ជាប់នេះ https://www.fcf-react.org/. ។

## ៥. សម្លេងកុមារ

ក្នុងវគ្គនេះមានការបញ្ចាំងវីដេអូខ្លីមួយដែលផលិតដោយអង្គការ This Life Cambodia ។ វីដេអូនេះបង្ហាញពីបទពិសោធន៍របស់ប្អូន សុក (ឈ្មោះដាក់ឱ្យក្រៅ) អាយុ១៨ឆ្នាំដែលធ្លាប់ជាប់ឃុំកាលពីវ័យ១៦ឆ្នាំដោយ ជាប់ចោទពីបទល្មើសពាក់ព័ន្ធនឹងគ្រឿងញៀន ហើយដែលបានចំណាយពេលអស់២ឆ្នាំនៅក្នុងពន្ធនាគារ។ សុក បានរៀបរាប់ពីបរិយាកាសរស់នៅដោយមានភាពកក់ក្តៅនៅក្នុងគ្រួសារ និងប្រកបដោយសេចក្តីស្រលាញ់ ប៉ុន្តែអ្វីៗត្រូវបានផ្លាស់ប្តូរនៅពេលដែលគ្រួសារផ្លាស់មករស់នៅក្នុងក្រុង។ មួយរយៈក្រោយមក មានការបែកបាក់នៅក្នុងគ្រួសារដោយសារតែឪពុកបានចាកចេញ ដែលនោះជាមូលហេតុចម្បងដែលនាំឱ្យ សុក ឈានទៅប្រើប្រាស់គ្រឿងញៀន រួមផ្សំជាមួយការអូសទាញពីមិត្តភក្តិ និងការពិបាកចិត្ត។

សុក ចំណាយពេល៦ខែក្នុងពន្ធនាគារ មុនពេលសវនាការ។ សុក មានរម្មណ៍សោកស្តាយ និងភ័យខ្លាចជាពុនពេកនៅក្នុងពន្ធនាគារ។ សុក នៅតែនឹកឃើញជានិច្ចថ្ងៃទី១នៅក្នុងពន្ធនាគារ ដែលខ្លួនបានទទួលការស្វាគមន៍ដោយការវាយដំពីអ្នកទោសមួយចំនួន ដែលមានបំណងវាយមកលើខ្លួនប្រាណ ដើម្បីកុំឱ្យឃើញរបួសស្នាម ព្រោះមានខោអាវបិទបាំង។ សុក រៀបរាប់ពីទុក្ខលំបាកនៅពេលគេង ដោយសារតែកន្លែងចង្អៀតប៉ុនប្រឡោះខ្លួន និង

មិនអាចរើខ្លួនបាន។ សុក បាននិយាយថា ពន្ធនាគារបានបន្សល់ទុកនូវអនុស្សាវរីយដ៏គួរឱ្យភ័យខ្លាច។ សុក មិនមានអាហារគ្រប់គ្រាន់ ទទួលរងការគំរាមកំហែង ហើយជារឿយៗមិនអាចងូតទឹកបានស្រួល។ មានបញ្ហាជាច្រើនដែល សុក ចង់ឃើញការផ្លាស់ប្តូរនៅក្នុងពន្ធនាគារ រួមមាន ការកែលំអគុណភាពនិងអនាម័យម្ហូបអាហារ ការបំបែកអនីតិជនចេញពីនីតិជន និងការគ្រប់គ្រងកុំឱ្យមានអំពើហិង្សាជាដើម។

រឿងទី១ ដែល សុក ចង់ធ្វើមុនគេបន្ទាប់ពីចេញពីពន្ធនាគារ គឺការសិក្សានិងការស្វែងរកការងារដើម្បីជួយដល់គ្រួសាររបស់ខ្លួន។ សុក មានចំណាប់អារម្មណ៍ចង់រៀនគ្រឿងអេឡិចត្រូនិក។ ពេលជាប់ឃុំក្នុងពន្ធនាគារ សុក នឹកដល់ម្តាយជាងគេ។ សុក បានប្រាប់ថាអ្នកម្តាយមិនដែលបោះបង់កូនឡើយក្នុងពេលដែលកូនជាប់ឃុំក្នុងពន្ធនាគារ ហើយក៏មិនដែលស្តីបន្ទោសកូនម្តងណាឡើយ។ អ្នកម្តាយតែងតែលើកទឹកចិត្តកូនឱ្យទទួលស្គាល់កំហុស និងត្រូវចេះកែប្រែ ហើយអ្នកម្តាយនៅតែផ្តល់សេចក្តីស្រឡាញ់មិនថាកូនមានបញ្ហាអ្វីឡើយ។ សុក បានបញ្ជាក់ថា អ្នកម្តាយបានជួយខ្លួនក្នុងគ្រាលំបាកក្នុងពន្ធនាគារ។ សុក បាននិយាយថា «គ្រួសាររបស់ខ្ញុំតែងតែផ្តល់សេចក្តីសង្ឃឹមនិងភាពញញឹមជានិច្ចដល់ខ្ញុំ»។ ក្រោយពេលចេញពីពន្ធនាគារ សុក ដឹងថានឹងទទួលរងការរើសអើង និងការនិយាយដើម ហើយថាឪពុកម្តាយអ្នកដទៃ នឹងមិនអនុញ្ញាតឱ្យកូនរបស់គេមកលេងជាមួយឡើយ។ សុក ពិបាកនឹងចេញពីផ្ទះ។ នៅពេល សុក វិលចូលសាលារៀនវិញ សុក មិនបាននិយាយប្រាប់អ្នកដទៃអំពីអតីតកាលនោះឡើយ ដោយសារខ្លាចមានការរើសអើងទៅលើខ្លួន និងគ្រួសាររបស់ខ្លួន។ ជាលទ្ធផលនៃការជាប់ពន្ធនាគារនេះ សុក បានបាត់បង់ឱកាសសិក្សារៀនជំនាញ និងឱកាសទទួលបានអនាគតល្អ។ យ៉ាងណាក៏ដោយ សុក បានបញ្ជាក់ថា គ្រួសារនៅតែផ្តល់សេចក្តីស្រឡាញ់ដល់ សុក ដដែល។ នៅចុងបញ្ចប់ សុកបានស្នើឱ្យរដ្ឋាភិបាលប្រើវិធានការផ្សេង ក្រៅពីបញ្ជូនអនីតិជនទៅដាក់ក្នុងពន្ធនាគារ គឺគួរផ្តល់ឱកាសដល់អនីតិជនបន្តការសិក្សា មានភាពកក់ក្តៅជាមួយគ្រួសារ ហើយវិធានការបែបនេះ អាចទប់ស្កាត់ការប៉ះពាល់ដល់សុខភាពផ្លូវចិត្តដែលកើតឡើងពីការជាប់ពន្ធនាគារទៀតផង។ សុក ក៏ចង់ឃើញផងដែរ ការបង្កើតឱ្យមានបណ្ណាល័យ និងថ្នាក់រៀននៅក្នុងពន្ធនាគារ ដែលសមរមសម្រាប់អនីតិជន ក៏ដូចជាការបន្តឱ្យមានកម្មវិធីបែបកុមារមេត្រី និងការធានាកុំឱ្យមានអំពើហិង្សាក្នុងពន្ធនាគារដើម្បីរក្សាបាននូវសុវត្ថិភាពសម្រាប់អនីតិជន។

អ្នកចូលរួមបានសម្តែងការកោតសរសើរ ដោយបង្ហាញថាវីដេអូខ្លីនេះ គឺពិតជាមានអត្ថន័យ និងមានភាពទាក់ទាញខ្លាំងណាស់។ អ្នកចូលរួមម្នាក់បានសម្តែងនូវក្តីសង្ឃឹមថាស្ថាប័នពាក់ព័ន្ធនឹងយកចិត្តទុកដាក់លើបញ្ហាទាំងឡាយដែលបានលើកឡើងដោយប្អូន សុក ហើយកែលំអស្ថានភាពដើម្បីឧត្តមប្រយោជន៍របស់អនីតិជន។ អ្នកចូលរួមម្នាក់ទៀតបានកត់សម្គាល់ថា វីដេអូខ្លីនេះបានឆ្លុះបញ្ចាំងការពិត និងជំរុញឱ្យមានចំណាត់ការជាបន្ទាន់ ដើម្បីបង្ការការឃុំឃាំងលើកកំពស់ការអនុវត្តវិធានការបង្វែរ ធានាឱ្យមានជំនួយផ្នែកច្បាប់ និងកែលំអស្ថានភាពអនីតិជនក្នុងពន្ធនាគារ។ អ្នកចូលរួមម្នាក់ទៀតបានលើកឡើងពីផលប៉ះពាល់ផ្លូវចិត្តដោយសារការជាប់ឃុំ ដូចសុកបានលើកឡើង ហើយដែលអ្នកជំនាញឯករាជ្យក៏បានឆ្លើយដែរថា មានកុមារជាច្រើនទទួលរងផលប៉ះពាល់សុខភាពផ្លូវចិត្តធ្ងន់ធ្ងរ បន្ថែមលើបញ្ហាសេដ្ឋកិច្ច និងផលវិបាកអវិជ្ជមានផ្សេងទៀតដែលកើតចេញពីការឃុំឃាំងនេះ ហើយថាបញ្ហានេះបង្កជាបញ្ហាលំបាកធ្ងន់ធ្ងរដល់កុមារនៅពេលត្រឡប់ចូលក្នុងសង្គមវិញ។

វីដេអូខ្លីរបស់ សុក គឺមាននៅក្នុងតំណភ្ជាប់នេះ
http://bit.ly/GSCDLCambodiaSok,
ហើយក៏មានផងដែរក្នុងបណ្តាញ Youtube
https://www.youtube.com/c/ThisLifeCambodia ។

បន្ទាប់ពីវីដេអូខ្លីនេះ ប្អូន អ៊ុយ តំណាងកុមារនៃបណ្តាញកុមារនិងយុវជន បានអានសេចក្តីថ្លែងការណ៍ស្តីពីការដកហូតសិទ្ធិសេរីភាពរបស់កុមារនៅកម្ពុជា ដែលរៀបចំដោយបណ្តាញកុមារនិងយុវជន ។ សេចក្តីថ្លែងការណ៍នេះលើកឡើងពីលទ្ធផលនៃកិច្ចពិភាក្សាជាមួយកុមារនិងយុវជនដែលបានធ្វើនៅមុនពេលពិធីផ្សព្វផ្សាយ ដែលក្នុងនោះរួមមានឧបសគ្គជាច្រើន ដែលអនីតិជនជួបនៅពេលត្រូវបានដកហូតសិទ្ធិសេរីភាព ដូចជាមានការលំបាកក្នុងការទទួលបានការសិក្សា ឧបសគ្គដល់ការអភិវឌ្ឍន៍អាកប្បកិរិយា បញ្ញា ស្មារតី និងសង្គម ខ្វះខាតអាហារូបត្ថម្ភ ផលប៉ះពាល់ដល់សុខភាពផ្លូវចិត្ត ការព្រួយបារម្ភដល់សុវត្ថិភាព និងផលប៉ះពាល់ក្រោយចេញពីពន្ធនាគារ។ សេចក្តីថ្លែងការណ៍ក៏បានលើកឡើងផងដែរពីដំណោះស្រាយមួយចំនួនដែលបានជួយដល់អនីតិជនក្នុងគ្រាលំបាក ដូចជា ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការទំនាក់ទំនងជាប្រចាំជាមួយបុគ្គលល្អៗ ការទំនាក់ទំនងជាប្រចាំជាមួយឪពុកម្តាយ និងបងប្អូនក្នុងសហគមន៍ខ្លួន។ សេចក្តីថ្លែងការណ៍នោះ ក៏បានលើកឡើងពីទស្សនៈរបស់កុមារនិងយុវជន ដែលមិនធ្លាប់មានបទពិសោធន៍ជាប់ឃុំ ដោយស្នើឡើងថា ការដកហូតសិទ្ធិសេរីភាពអនីតិជន ឬកុមារគួរត្រូវបានបង្ការទប់ស្កាត់ ហើយកុមារទាំងនេះគួរ

# ៥ សេចក្តីសង្ខេបស្តីពីពិធីផ្សព្វផ្សាយថ្នាក់ជាតិ

ត្រូវបានការពារ ហើយក៏ចង់ឱ្យការលើកឡើងទាំងនេះត្រូវបានដឹងឮដល់រដ្ឋាភិបាល។

ភ្ជាប់ជាមួយសេចក្តីថ្លែងការណ៍នេះ ក៏មានសំណើចំនួន ១០ដាក់ជូនរដ្ឋាភិបាលផងដែរ ដែលរួមមានដូចជាការធានាឱ្យមានការសិក្សាសមរម្យសម្រាប់កុមារ ឬអនីតិជន ដែលត្រូវបានដកហូតសិទ្ធិសេរីភាព ការកែលំអសេវា ថែទាំសុខភាពនិងម្ហូបអាហារ ការផ្តល់ឱកាសដល់កុមារក្នុងដំណើរការធ្វើការសម្រេចចិត្ត ការពង្រឹងវិធានការបង្ការទប់ស្កាត់ការដកហូតសិទ្ធិសេរីភាពដោយអនុវត្តវិធានការបង្វែរ និងជម្រើសផ្សេងក្រៅពីការឃុំខ្លួន និងការបង្កើតឱ្យមានកម្មវិធីល្អៗបែបកុមារមេត្រីនៅគ្រប់កន្លែងឃុំឃាំងទាំងអស់។

អ្នកចូលរួមបានសម្តែងការអបអរសាទរដល់កុមារដែលបានចូលរួមយោបល់ក្នុងពិធីនេះ និងសេចក្តីថ្លែងការណ៍ដែលឆ្លុះបញ្ចាំងពីសំឡេងរបស់កុមារដែលត្រូវស្តាប់ និងពិចារណា។ ឆ្លើយតបនឹងសេចក្តីថ្លែងការនោះ អ្នកចូលរួមម្នាក់បានលើកឡើងពីការលំបាករបស់មេធាវីក្នុងការផ្តល់សេវាផ្លូវច្បាប់ក្នុងដំណាក់កាលនគរបាល ហើយទទូចឱ្យរដ្ឋាភិបាលចាត់វិធានការសម្រួលឱ្យមានការផ្តល់សេវាផ្លូវច្បាប់សម្រាប់កុមារ។

សេចក្តីថ្លែងការណ៍របស់កុមារមាននៅក្នុងតំណភ្ជាប់នេះ៖ http://bit.ly/GSCDLCambodiaChildStatement ហើយក៏មាននៅក្នុងឧបសម្ពន្ធផងដែរ។

## ៦. ការឆ្លើយតបរបស់រដ្ឋាភិបាល

**ឯកឧត្តម ធូ ស៊ុន រដ្ឋលេខាធិការនៃក្រសួង ស.អ.យ.** បានឆ្លើយតបទៅនឹងសំណើរបស់កុមារ ដោយបានបញ្ជាក់ថា លោកបានពិនិត្យហើយនូវសំណើទាំង១០នោះ ដែលចំណុចខ្លះពាក់ព័ន្ធនឹងក្រសួង ស.អ.យ. ដោយផ្ទាល់។ លោកបានប្រកាសថា លោកទទួលយកសំណើទាំង១០ ក្នុងនាមក្រសួង ស.អ.យ. ហើយថាលោកនឹងពិភាក្សាសំណើទាំងនេះជាមួយក្រសួងពាក់ព័ន្ធដើម្បីកំណត់យុទ្ធសាស្ត្រអនុវត្តដោយផ្អែកលើធនធានដែលមាន។ លោកសង្ឃឹមថានឹងទទួលបានការគាំទ្រជាថវិកា សម្ភារៈ និង បច្ចេកទេសពីភ្នាក់ងារអង្គការសហប្រជាជាតិ សង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។ លោកក៏សង្ឃឹមដែរថា នឹងទទួលបានការខិតខំប្រឹងប្រែងទាំងអស់គ្នាដើម្បីដោះស្រាយជាជំហានៗនូវបញ្ហាដែលលើកឡើងដោយកុមារនិងយុវជន។

## ៧. សុន្ទរកថាបិទ

**លោកស្រី Foroogh Foyouzat តំណាង UNICEF កម្ពុជា** បានថ្លែងសុន្ទរកថាបិទពិធីនេះ។ លោកស្រីបានបញ្ជាក់ថា សិទ្ធិកុមារត្រូវបានរំលោភតាមបែបផ្សេងៗ នៅពេលដែលកុមារត្រូវបានដកហូតសិទ្ធិសេរីភាព ដែលផលប៉ះពាល់របស់វាមានរយៈពេលវែងជាងពេលជាប់ឃុំនោះទៅទៀត ដោយរួមទាំង ការទទួលរងការមាក់ងាយផង។ លោកស្រីបានសង្កត់ធ្ងន់លើលទ្ធផលនៃការសិក្សាជាសកល ដែលបង្ហាញថាមានកុមារប្រមាណជា ៧.២ លាននាក់នៅជុំវិញពិភពលោកដែលត្រូវបានគេដកហូតសិទ្ធិសេរីភាពជារៀងរាល់ឆ្នាំតាមទម្រង់ផ្សេងៗ។

លោកស្រីបានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការសំខាន់ៗមួយចំនួនដើម្បីកាត់បន្ថយការដាក់កុមារនៅក្នុងមណ្ឌល និងបានកែលំអប្រព័ន្ធយុត្តិធម៌អនីតិជនដែលរួមមានការអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជនក្នុងឆ្នាំ ២០១៦។ លោកស្រីបានបន្ថែមទៀតថា រដ្ឋាភិបាលថែមទាំងបានសម្តែងការប្តេជ្ញាចិត្តរបស់ខ្លួនតាម រយៈការចូលជាសមាជិកនៃក្រុមប្រទេសឈានមុខគេក្នុងការបញ្ចប់អំពើហិង្សាលើកុមារ។ លោកស្រីក៏បានលើកទឹកចិត្តរដ្ឋាភិបាលឱ្យអនុវត្តពេញលេញច្បាប់ស្តីពីយុត្តិធម៌អនីតិជន រួមទាំងបញ្ញត្តិពាក់ព័ន្ធនឹងវិធានការបង្វែរ និងវិធានការផ្សេងក្រៅពីការឃុំខ្លួន។ លោកស្រីបានលើកឡើងថា ក្នុងស្ថានភាពជំងឺរាតត្បាតកូវីដ១៩មានការកើនឡើងនៅកម្ពុជា ស្ថានភាពចង្អៀតណែននៅក្នុងពន្ធនាគារនិងមណ្ឌលមួយចំនួនអាចបង្កហានិភ័យដល់កុមារ ហេតុដូចនេះ រដ្ឋាភិបាលគួររិះរកវិធានការដោះលែងកុមារ។

លោកស្រីទទួលស្គាល់ថាមានការងារជាច្រើនដែលត្រូវធ្វើ ហើយថាការងារទាំងនោះត្រូវការកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងភាពជាដៃគូ ប៉ុន្តែយ៉ាងណាក៏ដោយលោកស្រីសម្តែងនូវក្តីសង្ឃឹមដោយឃើញការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល សង្គមស៊ីវិល ភ្នាក់ងារអង្គការសហប្រជាជាតិ រួមទាំងកុមារ និងយុវជននៅក្នុងពិធីផ្សព្វផ្សាយនេះ។ លោកស្រីបញ្ជាក់ថា អនុសាសន៍សំខាន់ៗនៅក្នុងការសិក្សាជាសកលនេះ

បង្ហាញផ្លូវច្បាស់លាស់ទៅកាន់វឌ្ឍនៈភាពដើម្បីការពារ និងលើកកំពស់សិទ្ធិកុមារ និងចូលរួមសម្រេចបាននូវគោលការណ៍នៃទិសដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។ នៅទីបញ្ចប់ លោកស្រីបានមានប្រសាសន៍ថា ពិធីផ្សព្វផ្សាយថ្នាក់ជាតិនេះ គឺជាជំហានដ៏សំខាន់នៅកម្ពុជា ឆ្ពោះទៅបញ្ចប់ការដកហូតសិទ្ធិសេរីភាពកុមារ ហើយលោកស្រីមានភាពជឿជាក់ថា តាមរយៈកិច្ចខិតខំរួមគ្នានេះ កម្ពុជាអាចមានបទពិសោធន៍ល្អជាងគេនៅក្នុងតំបន់ដែលអាចជាប្រទេសគំរូសម្រាប់ឱ្យប្រទេសផ្សេងអនុវត្តតាម។

## ៨. កិច្ចប្រជុំត្រៀមរៀបចំសន្និសីទពិភពលោក២០២១ ស្ដីពីយុត្តិធម៌កុមារ

បន្ទាប់ពីបញ្ចប់ពិធីផ្សព្វផ្សាយថ្នាក់ជាតិភ្លាម ក្រុមការងារបច្ចេកទេសសម្រាប់ត្រៀមរៀបចំសន្និសីទពិភពលោក បានចាប់ផ្ដើមភ្លាមដោយមានការចូលរួមពីមន្ត្រីបច្ចេកទេសនៃភ្នាក់ងារអង្គការសហប្រជាជាតិ រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍កុមារ និងយុវជន។ គោលបំណងនៃកិច្ចប្រជុំនេះគឺកំណត់បញ្ហាប្រឈមនិងការងារអាទិភាពទាក់ទងនឹងយុត្តិធម៌កុមារ ឬអនីតិជននៅកម្ពុជា កំណត់ការអនុវត្តល្អ និងពិភាក្សារកដំណោះស្រាយពង្រឹងកិច្ចសហការឱ្យកាន់តែមានប្រសិទ្ធភាពក្នុងចំណោមស្ថាប័នពាក់ព័ន្ធ។

លទ្ធផលនៃការអង្កេតមុនកិច្ចប្រជុំត្រូវបានបង្ហាញដោយរួមមានបញ្ហាប្រឈមចម្បងៗមួយចំនួនដូចជា ខ្វះនីតិវិធីកុមារមេត្រីនៅគ្រប់ដំណាក់កាលនៃប្រព័ន្ធតុលាការ ខ្វះការអនុវត្តវិធានការបង្វែរនិងជម្រើសផ្សេងក្រៅពីការឃុំខ្លួន ខ្វះជំនួយផ្នែកច្បាប់(មេធាវី)ក្នុងកំឡុង២៤ម៉ោងនៃការចាប់ខ្លួន រួមទាំងពុំសូវមានការផ្ដោតលើការធ្វើសមាហរណកម្ម និងការស្ដារនីតិសម្បទា។ កុមារនិងយុវជនបានកំណត់បញ្ហាប្រឈមមួយចំនួនដូចជា ការខ្វះខាតការ ផ្ដោតលើវិធានការនិងនីតិវិធីគ្រប់ជ្រុងជ្រោយ និងការខ្វះខាតព័ត៌មានទាក់ទងនឹងកុមារនៅក្នុងប្រព័ន្ធ។ ការងារ អាទិភាពរួមមានការអនុវត្តន៍កម្មវិធីបង្វែរជាផ្លូវការនិងវិធានការឬជម្រើសផ្សេងក្រៅពីការឃុំខ្លួន កសាងសមត្ថភាពមន្ត្រីយុត្តិធម៌ ការបង្កើតនិងការប្រើប្រាស់នីតិវិធីកុមារមេត្រីនៅក្នុងតុលាការ និងការិយាល័យនគរបាល រួមទាំងការពង្រឹងសេវាផ្នែកច្បាប់សម្រាប់កុមារ។

ពាក់ព័ន្ធនឹងគោលការណ៍មិនរើសអើង និងការទទួលបានយុត្តិធម៌ ដែលជាប្រធានបទមួយសំខាន់នៅក្នុងសន្និសីទពិភពលោក២០២១ស្ដីពីយុត្តិធម៌កុមារ ដែលនឹងប្រព្រឹត្តទៅតាមអនឡាញនៅថ្ងៃទី ១៥ដល់២០ វិច្ឆិកា ២០២១ លទ្ធផលនៃការអង្កេតបានកំណត់ការងារអាទិភាពមួយចំនួនរួមមានការធានាឱ្យមានការផ្ដល់សេវាបែបកុមារមេត្រីស្មើៗគ្នាសម្រាប់កុមាររងគ្រោះ កុមារជាសាក្សី និង កុមារប្រព្រឹត្តបទល្មើស ធានាថាសំឡេងកុមារត្រូវបានទទួលយកនៅក្នុងប្រព័ន្ធយុត្តិធម៌ ដោះស្រាយបញ្ហារើសអើងដោយសារភាពក្រីក្រនិងបទល្មើសទាក់ទងនឹងគ្រឿងញៀន រួមទាំងការផ្ដល់សេវាស្មើៗគ្នាសម្រាប់កុមារនៅជនបទ។ កុមារនិងយុវជនក៏បានឯកភាពដែរថា វាជារឿងសំខាន់ដែលត្រូវដោះស្រាយបញ្ហារើសអើងដោយសារតែពិការភាព ឬស្ថានភាពសុខភាព បញ្ហាយេនឌ័រ ជនជាតិភាគតិច សាសន៍ ក្រុមភាគតិច។

បន្ទាប់ពីបទបង្ហាញនេះ មានបទបង្ហាញខ្លីៗដែលត្រូវបានធ្វើឡើងដោយអង្គការក្នុងស្រុកដែលអនុវត្តការងារនេះ។ អង្គការ Hagar International បាននិយាយពីគោលការណ៍ណែនាំស្ដីពីនីតិវិធីបែបកុមារមេត្រីសម្រាប់កុមារដែលនឹងត្រូវបានអនុម័តដោយក្រសួងយុត្តិធម៌ អង្គការ LAC បានបង្ហាញពីនីតិវិធីនគរបាលបែបកុមារមេត្រី អង្គការ Action Pour Les Enfants បានចែករំលែកពីការងារពាក់ព័ន្ធនឹងការបង្កើតបន្ទប់សម្ភាសន៍បែបកុមារមេត្រី អង្គការ Cambodian Center for Human Rights បាននិយាយពីការងារត្រួតពិនិត្យមើលសវនាការសំណុំរឿងព្រហ្មទណ្ឌពាក់ព័ន្ធនឹងកុមារនៅសាលាឧទ្ធរណ៍រាជធានីភ្នំពេញ និងអង្គការ This Life Cambodia បានបង្ហាញពីកម្មវិធីរបស់ខ្លួនពាក់ព័ន្ធនឹងយុត្តិធម៌កុមារដែលរួមមានដូចជាការជួយគាំទ្រដល់កុមារនិងគ្រួសារទាំងពេលមុន អំឡុងពេល និង ក្រោយពេលជាប់ឃុំ។ បន្ថែមលើសនេះ UNICEF បានឱ្យដឹងពីវឌ្ឍនៈភាពនៃគោលការណ៍ណែនាំស្ដីពីការបង្វែរដែលកំពុងត្រូវបានកែសម្រួលចុងក្រោយដើម្បីឈានទៅអនុម័តដោយក្រសួង ក.យ. កម្មវិធីបណ្ដុះបណ្ដាលស្ដីពីកិច្ចការពារកុមារដល់មន្ត្រីនគរបាលថ្នាក់ខេត្ត និងស្រុកក្នុងខេត្តគោលដៅចំនួន ៥ និងការអនុម័តរបស់រដ្ឋមន្ត្រីក្រសួង ស.អ.យ. លើទម្រង់របាយការណ៍ស្ដីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនទំនាស់នឹងច្បាប់។

ព័ត៌មានលំអិតពាក់ព័ន្ធនឹងកិច្ចប្រជុំរៀបចំនេះមាននៅក្នុងរបាយការណ៍សង្ខេបដាច់ដោយឡែក។

# ៦ អ្នកចូលរួម

ពិធីផ្សព្វផ្សាយថ្នាក់ជាតិនេះ មានអ្នកចុះឈ្មោះចំនួន ២៥០នាក់ ក្នុងនោះមានអ្នកបានចូលរួមចំនួន ១៨៨ នាក់ ដែលបានភ្ជាប់ទៅនឹងពិធីនេះដោយផ្ទាល់។ គួរកត់សម្គាល់ថាករណីអ្នកចូលរួមខ្លះ មានការចូលរួមស្ដាប់រួមគ្នាជាមួយអ្នកចូលរួមផ្សេងទៀតដែលមិនមានគណនីអ៊ីមែល។ ដូចនេះ បើគិតសរុប មានអ្នកចូលរួមទាំងអស់ប្រមាណជា ២០០នាក់ រួមទាំងថ្នាក់ដឹកនាំជាន់ខ្ពស់ តំណាងក្រសួងសំខាន់ៗ ចំនួនបី។ ក្នុងចំណោមម្ចាស់គណនីអ៊ីមែលចំនួន ១៨៨នាក់ មានស្ត្រីចំនួន ៧៦នាក់ ១០៨នាក់ ជាបុរស និង ៤នាក់ មិនបានបញ្ជាក់ភេទ។ លើសពីនេះទៀត មានកុមារអាយុក្រោម១៨ឆ្នាំចំនួន ៧នាក់បានចូលរួម ៤១នាក់ជាយុវជនចំនោះ១៨ និង២៤ឆ្នាំ ហើយ១៤០នាក់ជានីតិជនអាយុលើស២៤ឆ្នាំ។

អ្នកចុះឈ្មោះមានជម្រើសក្នុងការបង្ហាញឬមិនបង្ហាញទីកន្លែងការងាររបស់ខ្លួន។ ផ្អែកលើការបង្ហាញអត្តសញ្ញាណកន្លែងការងារ គឺមានអ្នកចូលរួមពីអង្គការក្នុងស្រុកចំនួន ៣១ អង្គការបរទេសចំនួន៨ ភ្នាក់ងារអង្គការសហប្រជាជាតិចំនួន៤ ដៃគូអភិវឌ្ឍន៍ចំនួន៦ អង្គការដឹកនាំដោយកុមារ និងយុវជននានា អ្នកអប់រំ អ្នកគ្រប់គ្រងគ្រឹះស្ថានសិក្សាចំនួន៧ អ្នកសារព័ត៌មានចំនួន២ មេធាវីជាច្រើននាក់ និងអ្នកប្រកបវិជ្ជាជីវៈច្បាប់ផ្សេងទៀត អ្នកជំនាញឯករាជ្យ និស្សិត អ្នកធ្វើការស្ម័គ្រចិត្ត បុគ្គលិកក្រុមហ៊ុនឯកជន និងសមាជិកអ្នកចូលរួមក្នុងប្រទេស និងក្រៅប្រទេស។

សមាសភាពអ្នកចូលរួមខាងរដ្ឋាភិបាលនិងស្ថាប័នពាក់ព័ន្ធ មាន៖

| | |
|---|---|
| **ក្រសួង ក.យ** | • រដ្ឋលេខាធិការទទួលបន្ទុកទំនាក់ទំនងជាមួយអគ្គនាយកដ្ឋានកិច្ចការអយ្យការនិងព្រហ្មទណ្ឌ ពន្ធនាគារ នគរបាលយុត្តិធម៌ ការលើកលែងទោសនិងបន្ធូរបន្ថយទោស<br>• រដ្ឋលេខាធិការទទួលបន្ទុកកិច្ចការពាក់ព័ន្ធនឹងអគ្គនាយកដ្ឋានរដ្ឋប្បវេណី ការផ្សព្វផ្សាយនិងការបណ្ដុះបណ្ដាលច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ<br>• ប្រធាននាយកដ្ឋានកិច្ចការព្រហ្មទណ្ឌនិងយុត្តិធម៌អនីតិជន<br>• ចៅក្រមនៃសាលាដំបូង |
| **ក្រសួង ម.ផ** | • រដ្ឋលេខាធិការទទួលបន្ទុកកិច្ចការយុត្តិធម៌អនីតិជន<br>• អនុរដ្ឋលេខាធិការទទួលបន្ទុកយុត្តិធម៌អនីតិជន<br>• អគ្គនាយក និងអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធនាគារ<br>• ប្រធានមណ្ឌលអប់រំកែប្រែ២ និងប្រធានពន្ធនាគារខេត្តសៀមរាប |
| **ក្រសួង ស.អ.យ.** | • រដ្ឋលេខាធិការទទួលបន្ទុកយុត្តិធម៌អនីតិជន<br>• អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស<br>• ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ<br>• ប្រធាននាយកដ្ឋានយុវនីតិសម្បទា |
| **គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា** | • អគ្គលេខាធិការរង<br>• អនុប្រធាននាយកដ្ឋានការពារជនក្រីក្រ |

ក្រៅពីនេះក៏មានការចូលរួមពីបុគ្គលិកក្រសួងអប់រំ យុវជន និង កីឡា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

# ជំហានបន្ទាប់ ៧

**ពិធីផ្សព្វផ្សាយថ្នាក់ជាតិនេះ គឺជាជំហានវិជ្ជមានមួយឆ្ពោះទៅរកចំណាត់ការរួមគ្នាដើម្បីទប់ស្កាត់ និងដោះស្រាយការដកហូតសិទ្ធិសេរីភាពកុមារ ប៉ុន្តែនៅមានកិច្ចការសំខាន់ៗជាច្រើន ដែលត្រូវធ្វើជាបន្ទាប់។ ខាងក្រោមនេះ គឺជាការងារចម្បងៗ ដែលគណៈកម្មាធិការរៀបចំត្រូវតាមដានជាមួយស្ថាប័នពាក់ព័ន្ធឯទៀត៖**

១. តាមដានជាមួយក្រសួង ស.អ.យ. ក្រសួង ម.ផ. ក្រសួង ក.យ. និង ក.ជ.ក ទៅលើសេចក្តីថ្លែងការណ៍រួមស្តីពីការប្តេជ្ញាចិត្តពាក់ព័ន្ធនឹងកុមារ ដែលត្រូវបានដកហូតសិទ្ធិសេរីភាព ពោលគឺការអនុម័តលើសេចក្តីថ្លែងការណ៍នេះ ការរៀបចំពិធីរំលឹកព្រឹត្តិការណ៍នេះដែលដឹកនាំដោយរដ្ឋាភិបាល និងការដាក់បញ្ចូលសកម្មភាពទៅក្នុងផែនការរបស់ក្រសួងពាក់ព័ន្ធ

២. ការតាមដានជាមួយក្រសួងទាំងបីលើផែនការសកម្មភាពរយៈពេលយូរ ដើម្បីឆ្លើយតបទៅនឹងសំណើទាំង១០ របស់កុមារនិងយុវជន ដែលត្រូវបានទទួលយកដោយឯកឧត្តម ធូ ស៊ុន ក្នុងពេលពិធីផ្សព្វផ្សាយ

៣. តាមដានជាមួយសង្គមស៊ីវិល និងដៃគូផ្សេងទៀត ពាក់ព័ន្ធនឹងយុទ្ធសាស្ត្រក្នុងការបង្កើតក្រុមការងារ និងក្រុមអ៊ីមែលស្តីពីយុត្តិធម៌អនីតិជន ឬ កុមារដូចដែលបានពិភាក្សាក្នុងកិច្ចប្រជុំត្រៀមរៀបចំ និង

៤. ពិភាក្សាជាមួយភាគីពាក់ព័ន្ធថាតើត្រូវធ្វើដូចម្តេចដើម្បីផ្សាភ្ជាប់កិច្ចខិតខំប្រឹងប្រែងនៅក្នុងស្រុកទៅថ្នាក់ តំបន់ និងកម្រិតអន្តរជាតិក្នុងគោលបំណងចែករំលែកបទពិសោធន៍និងសិក្សាពីគ្នាទៅវិញទៅមក និងកែលំអប្រព័ន្ធយុត្តិធម៌អនីតិជននៅកម្ពុជា រួមទាំងការចូលរួមក្នុងសន្និសីទពិភពលោក២០២១ស្តីពីយុត្តិធម៌អនីតិជនផងដែរ។

# ៨ ឧបសម្ពន្ធ

### សេចក្តីថ្លែងការណ៍រួម

### ស្តីអំពី

### ការដកហូតសិទ្ធិសេរីភាពកុមារនៅក្នុងប្រទេសកម្ពុជា

### ដោយបណ្តាញដែលដឹកនាំដោយកុមារ និងយុវជន

២២ មេសា ២០២១

នាថ្ងៃផ្សព្វផ្សាយថ្នាក់ជាតិអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវជាសកលរបស់អង្គការសហប្រជាជាតិស្តីពីការដកហូតសិទ្ធិសេរីភាពកុមារនៅក្នុងប្រទេសកម្ពុជា យើងខ្ញុំសូមបង្ហាញនូវការគាំទ្រយ៉ាងពេញទំហឹងទៅលើកុមារគ្រប់រូបដែលកំពុងប្រឈមមុខនឹងការដកហូតសិទ្ធិសេរីភាពនៅក្នុងប្រទេស។

កុមារមួយចំនួនត្រូវបានដកហូតសិទ្ធិសេរីភាពក្នុងស្ថានភាព និង ទីកន្លែងខ្លះនៅក្នុងប្រទេសកម្ពុជា ដែលរួមមានដូចជា ពន្ធនាគារ ទីស្នាក់ការនគរបាល មណ្ឌលថែទាំជំនួស (ដូចជាមណ្ឌលកុមារកំព្រាជាដើម) មណ្ឌលស្តារនីតិសម្បទា និងមណ្ឌលមួយចំនួនផ្សេងទៀត។ ការរីកចម្រើនគួរឱ្យកត់សម្គាល់របស់រាជរដ្ឋាភិបាល កំពុងឆ្ពោះទៅរកការដោះស្រាយស្ថានភាពកុមារដែល ត្រូវបានគេដកហូតសិទ្ធិសេរីភាព ដោយលើកកម្ពស់ការការពារនិងសុខសុវត្ថិភាពសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា។ តែទោះបីជាយ៉ាងណា ក៏នៅតែមានកិច្ចការសំខាន់ខ្លះទៀតដែលត្រូវធ្វើ តទៅទៀត។

យើងខ្ញុំមិនអាចបកស្រាយជំនួសកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាព ដែលគ្មានឱកាសចូលរួមជាមួយយើងខ្ញុំនៅថ្ងៃនេះទេ ប៉ុន្តែយើងខ្ញុំអាចដឹងឮពីកុមារមួយចំនួនដោយផ្ទាល់ ហើយយើងខ្ញុំចង់ពាំនាំនូវសំឡេងរបស់ពួកគាត់ក្នុងការពិភាក្សាថ្នាក់ជាតិនេះ។

ក្នុងរយៈពេលពីរខែកន្លងមកនេះ យើងខ្ញុំបានធ្វើការពិគ្រោះយោបល់ជាមួយកុមារដែលត្រូវ បានដកហូតសិទ្ធិសេរីភាព ក៏ដូចជាកុមារ និងយុវជនដែលមិនធ្លាប់បានឆ្លងកាត់ហេតុការណ៍ទាំងនេះ រួមទាំងបុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងផ្ទាល់ជាមួយអ្នកដែលត្រូវបានគេដកហូត សិទ្ធិសេរីភាពកាលពីកុមារភាពផងដែរ។ យើងក៏បានបង្រួបបង្រួមសំលេងផ្ទាល់របស់កុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាព ដែលត្រូវបានគូសបញ្ជាក់នៅក្នុងការសិក្សាស្រាវជ្រាវថ្មីៗដែលធ្វើឡើង ដោយអង្គការសង្គមស៊ីវិលក្នុងស្រុក។

ផ្អែកលើលទ្ធផលទាំងនេះ យើងខ្ញុំឃើញថា កុមារជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន អំឡុងពេល និងបន្ទាប់ពីពួកគាត់ត្រូវបានដកហូតសិទ្ធិសេរីភាព។

- ១ -

សេចក្តីថ្លែងការណ៍រួមស្តីពីការដកហូតសិទ្ធិសេរីភាពកុមារនៅកម្ពុជា ដោយបណ្តាញដឹកនាំដោយកុមារនិងយុវជន មានក្នុងតំណភ្ជាប់នេះ៖ http://bit.ly/GSCDLCambodiaChildStatement)

បញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ៗ ដែលបានលើកឡើងនោះ គឺកង្វះលទ្ធភាពក្នុងការទទួលបានការសិក្សាអប់រំ និងសម្ភារសិក្សាមូលដ្ឋាន រួមជាមួយនឹងគុណភាពនៃកម្មវិធីនៅមានកម្រិតទាបនៅឡើយ។ កត្តាទាំងនេះបានផ្សារភ្ជាប់ទៅនឹងផលប៉ះពាល់អវិជ្ជមាន ទៅលើភាពមានការងារធ្វើនៅថ្ងៃអនាគត កង្វះសេរីភាព និងឱកាសក្នុងការចូលរួម និង ពេលវេលាផ្ទាល់ខ្លួន។ កុមារ និងយុវជនបានចង្អុលបង្ហាញថា ការដកហូតសិទ្ធិសេរីភាពប្រៀបបាន ទៅនឹងឧបសគ្គរាំងស្ទះការអភិវឌ្ឍន៍សង្គម ចំណេះដឹង និងការអភិវឌ្ឍន៍អាកប្បកិរិយារបស់កុមារ រួមជាមួយនិងការគោរពខ្លួនឯង ក្រមសីលធម៌ ការយល់ដឹងពីសង្គម និងភាពសប្បាយរីករាយនិងការលើកទឹកចិត្តនៅក្នុងជីវិត។ លើសពីនេះទៅទៀត កង្វះអាហារដែលមានជីវជាតិគ្រប់គ្រាន់បណ្តាលឱ្យមានកង្វះអាហារូបត្ថម្ភ រឺឯកង្វះអនាម័យ និងសេវាថែទាំសុខភាពនាំឱ្យប៉ះពាល់ដល់សុខភាពរាងកាយរបស់កុមារ។ ពួកគាត់ក៏ទទួលរងនូវភាពស្មុគស្មាញនៃសម្ពាធផ្លូវចិត្ត រួមទាំងភាពតានតឹងផ្លូវចិត្ត ការបាក់ទឹកចិត្ត និងគំនិតក្នុងការធ្វើអត្តឃាតជាដើម។

កុមារនិងយុវជនបានបង្ហាញថាពួកគាត់មិនទទួលបាននូវការផ្តល់ព័ត៌មានសមស្របអំពីអ្វីដែលកំពុងកើតឡើង និងអ្វីដែលនឹងកើតឡើងចំពោះពួកគេទៅថ្ងៃខាងមុខនោះទេ ហើយពួកគេមិនត្រូវបានផ្តល់ឱកាសគ្រប់គ្រាន់ដើម្បីចូលរួម និងមានសំឡេងក្នុងការធ្វើសេចក្តីសម្រេចចិត្ត រួមទាំងដំណើរការរៀបចំផែនការសម្រាប់ការធ្វើសមាហរណកម្មនោះទេ។ ពួកគេបានបង្ហាញថា ការបែកបាក់ពីគ្រួសារ ប៉ះពាល់ដល់ទំនាក់ទំនងនៅក្នុងគ្រួសារ ជីវភាពរស់នៅ និងខ្លះទៀត មានការព្រួយបារម្ភណ៍ដោយសារពួកគេត្រូវបានបំភ្លេចដោយសមាជិកគ្រួសារ។ ទីកន្លែងឃុំឃាំង មួយចំនួនខ្វះភាពកក់ក្តៅសម្រាប់កុមារ ហើយកុមារមិនអាចប្រាស្រ័យទាក់ទងគ្នាបានស្រួល ដោយសារតែមានភាពចង្អៀតណែន និងនៅលាយឡំជាមួយនីតិជនដែលកត្តានេះអាចជះឥទ្ធិពលមិនល្អ និងបង្កជម្លោះជាដើម។ កុមារ និងយុវជនបានបង្ហាញពីការព្រួយបារម្ភណ៍ចំពោះសុវត្ថិភាព និងការភ័យខ្លាចចំពោះការប្រើប្រាស់អំពើហិង្សាគ្រប់ទម្រង់ដែលប្រព្រឹត្តដោយបុគ្គលិកនិងមនុស្សធំរួមមានការរំលោភបំពានលើផ្លូវកាយ និងផ្លូវចិត្ត ការរើសអើង និងការមិនអើពើជាដើម។

បន្ថែមពីនេះទៀត កុមារ និងយុវជនបានទទួលនូវបញ្ហាដោយសារផលប៉ះពាល់យូរអង្វែង នៃការដកហូតសិទ្ធិសេរីភាព។ ការមើលងាយនៅក្នុងសាលារៀន និងនៅក្នុងសហគមន៍ អាចនឹងធ្វើឱ្យកុមារមានភាពឯកោ និងមានការភ័យខ្លាចក្នុងការទំនាក់ទំនងជាមួយអ្នកដទៃ ដែលធ្វើឱ្យកុមារបាត់បង់ឱកាសក្នុងការធ្វើ សមាហរណកម្មទៅក្នុងសង្គម។ កុមារក៏បានបន្ថែមថាពួកគេ ប្រឈមនឹងអស្ថេរភាពខាងផ្លូវចិត្ត និងការបាត់បង់ឪកាសក្នុងការសិក្សាអប់រំ និងការងារដែលបណ្តាលឱ្យមានផលវិបាកផ្ទាល់ខ្លួននឹងផ្តល់ផលប៉ះពាល់ អវិជ្ជមានដល់ស្ថានភាពសេដ្ឋកិច្ចផ្ទាល់ខ្លួន និងគ្រួសារ។

ក៏ប៉ុន្តែកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាពបានបញ្ជាក់ថាមានកម្មវិធីមួយចំនួនដែលជួយឱ្យពួកគេជម្នះពេលវេលាដ៏លំបាកមួយពោលគឺ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអភិវឌ្ឍន៍ខ្លួន មិនត្រឹមតែជួយដល់កុមារក្នុងការកសាងជំនាញរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែកម្មវិធីនេះក៏បានធ្វើឱ្យប្រសើរឡើងនូវសុខភាព និងអារម្មណ៍រួមជាមួយនឹងក្តីសង្ឃឹមសម្រាប់កសាងអនាគតដ៏ប្រសើរ។ ការទំនាក់ទំនងជាប្រចាំ

- ២ -

ជាមួយនឹងបុគ្គលគំរូណាម្នាក់នៅខាងក្រៅអង្គការ តាមរយៈកម្មវិធីនានា ផ្តល់ឱ្យពួកគេនូវសារប្រយោជន៍ដល់សុខុមាលភាព និងការធ្វើសមាហរណកម្ម។ ស្រដៀងគ្នានេះដែរ ពួកគេបានឱ្យដឹងថា ទំនាក់ទំនងជាប្រចាំជាមួយនឹងសមាជិកគ្រួសារ និងសហគមន៍ ជួយកសាងទំនាក់ទំនងដ៏រឹងមាំក្នុងអំឡុងពេលនិងបន្ទាប់ពីការដកហូតសិទ្ធិសេរីភាពរបស់កុមារ។

កុមារ និងយុវជនដែលមិនមានបទពិសោធន៍ត្រូវបានដកហូតសិទ្ធិសេរីភាពបានប្តេជ្ញាសម្រេចជាផ្តត់គំនិតមួយគឺ ការដកហូតសិទ្ធិសេរីភាពគួរតែត្រូវបានទប់ស្កាត់ ហើយកុមារគួរតែត្រូវបានការការពារ។ ក្រៅពីនេះ កុមារទាំងអស់បានបង្ហាញនូវបំណងប្រាថ្នាមួយដើម្បីអាចបញ្ចេញនូវសំឡេងរបស់ពួកគាត់ទៅដល់រដ្ឋាភិបាល និងចូលរួមក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តនានា។

ដោយផ្អែកលើធាតុចូលដែលទទួលបានពីកុមារនិងយុវជន យើងខ្ញុំសូមធ្វើការស្នើសុំដល់ក្រសួងដែលពាក់ព័ន្ធនៃរដ្ឋាភិបាលកម្ពុជា ដូចខាងក្រោម៖

១. **ធានាឱ្យមានសិទ្ធិស្មើគ្នាក្នុងការទទួលបានការសិក្សាអប់រំដ៏ត្រឹមត្រូវ** សម្រាប់កុមារដែល ត្រូវបានដកហូតសិទ្ធិសេរីភាព រួមទាំងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងឱកាសកសាងជំនាញ។

២. **ពង្រឹងសេវាថែទាំសុខភាព និងការទទួលបានអាហារដែលមានជីវជាតិគ្រប់គ្រាន់** សម្រាប់កុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាព រួមទាំងសេវាគាំទ្រចិត្តសាស្ត្រ និងការប្រឹក្សាយោបល់។

៣. **ផ្តល់អំណាច**ឱ្យកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ហើយ**ផ្តល់ឱកាសឱ្យពួកគាត់ចូលរួមក្នុងការធ្វើការសម្រេចចិត្ត** ក្នុងលក្ខណៈមួយដែលមាន ឥទ្ធិពលលើការផ្លាស់ប្តូរក្នុងកម្រិតបុគ្គល ឬជាប្រព័ន្ធ។

៤. **ពង្រឹងវិធានការដើម្បីទប់ស្កាត់**ការដកហូតសិទ្ធិសេរីភាពរបស់កុមារ រួមទាំងការពង្រឹងយន្តការការពារកុមារ ការកែលំអទៅលើប្រព័ន្ធអប់រំទូទៅ និងការពង្រឹងការគាំទ្រពីគ្រួសារ។

៥. **អនុវត្តវិធានការបង្វែរ និងជម្រើសផ្សេងក្រៅពីការឃុំខ្លួន** សម្រាប់កុមារទំនាស់នឹងច្បាប់។

៦. **បង្កើតនីតិវិធីបែបកុមារមេត្រី** សម្រាប់អនុវត្តនៅទីកន្លែងដែលមានការដកហូតសិទ្ធិសេរីភាពកុមារ ហើយកសាងសមត្ថភាពនៃអ្នកគ្រប់គ្រង និងបុគ្គលិកនៅទីកន្លែងនោះ ដើម្បីបង្កើនគុណភាពនៃប្រតិបត្តិការរបស់ពួកគាត់ក្នុងលក្ខណៈកុមារមេត្រី និងធានាបាននូវការគោរពសិទ្ធិកុមារ។

៧. **ទប់ស្កាត់អំពើហិង្សា**លើកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាព រួមទាំងការកាត់បន្ថយនូវវិន័យ និងការពិន័យលើរូបរាងកាយនៅតាមកន្លែងនីមួយៗ ការហាមឃាត់ការរើស អើង និងការតាមដានយ៉ាងម៉ឺងម៉ាត់ចំពោះអំពើហិង្សាដែលបានកើតឡើង។

- ៣ -

៨. **ផ្តល់សេវាកម្មជាលក្ខណៈឯកត្តជននិងការយកចិត្តទុកដាក់** ទៅលើកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាពដោយផ្អែកលើតម្រូវការជាក់លាក់របស់ពួកគាត់ រួមទាំងកុមារពិការ កុមារី និងកុមារដែលមានផ្ទៃពោះ កុមារដែលមកពីជនបទ កុមារដែលខ្វះការអប់រំ និងកុមារដែលទទួលរងគ្រោះពីការប្រើប្រាស់ថ្នាំញៀន និងសារធាតុខុសច្បាប់។

៩. **ផ្តល់ទីកន្លែងស្នាក់នៅជាមួយនឹងការគាំទ្រទាំងផ្នែកសម្ភារៈនិងថវិកា** រួមទាំងសម្ភារសិក្សា និងឧបករណ៍កំសាន្តផងដែរ។

១០. **អនុម័តច្បាប់ការពារកុមារ** ដែលផ្តោតសំខាន់លើការបង្រួបបង្រួមគ្រួសាររបស់ពួកគេ លើកកម្ពស់ការយល់ដឹងពីសិទ្ធិកុមារ និងច្បាប់ដែលចែងពាក់ព័ន្ធទៅនឹងកុមារ អ្នកមើលថែទាំ សហគមន៍ និងគ្រប់ទីកន្លែងដែលមានការដកហូតសិទ្ធិសេរីភាពរបស់កុមារ។

សេចក្តីថ្លែងការណ៍នេះត្រូវបានរៀបចំរួមគ្នាដោយ ក្រុមតំណាងយុវវ័យនិងយុវជន (AYRG) បណ្តាញកុមារអ្នកតស៊ូមតិ (CAN) និងសមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ (CCYMCR) ជាមួយនឹងការគាំទ្រពីសំណាក់អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា (CRC-Cambodia)។

- ៤ -

# ៨

**ឧបសម្ពន្ធ** សេចក្តីថ្លែងការណ៍រួមរបស់សង្គមស៊ីវិលស្តីពីការជួយគាំទ្រដល់កុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាពនៅកម្ពុជា មានក្នុងតំណភ្ជាប់នេះ: http://bit.ly/GSCDLCambodiaCivilSocietyStatement)

## សេចក្តីថ្លែងការណ៍រួម
## របស់សង្គមស៊ីវិល
## ស្តីពីការដកហូតសិទ្ធិសេរីភាពកុមារនៅប្រទេសកម្ពុជា

*រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០២១*

យើងជាអង្គការដែលបានចុះហត្ថលេខា សូមអបអរសាទរដល់ការផ្សព្វផ្សាយថ្នាក់ជាតិអំពីការសិក្សាស្រាវជ្រាវជាសកលរបស់អង្គការសហប្រជាជាតិ ស្តីពីការដកហូតសិទ្ធិសេរីភាពកុមារ (ការសិក្សា ជាសកល) ដែលរៀបចំឡើងនៅក្នុងប្រទេសកម្ពុជាថ្ងៃនេះ។

យើងសូមកោតសរសើរ និងគោរពសំឡេងរបស់កុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាពហើយដែលបានលើកឡើងនៅក្នុងការផ្សព្វផ្សាយថ្នាក់ជាតិ តាមរយៈការចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួន និងសេចក្តីថ្លែងការណ៍រួមនៃបណ្តាញដែលដឹកនាំដោយកុមារនិងយុវជន ដែលបង្ហាញពីបញ្ហាប្រឈមដែលកុមារទាំងនោះបានជួបប្រទះ និងសំណូមពររបស់ពួកគេទៅកាន់រដ្ឋាភិបាលកម្ពុជា។ យើងយល់ពីបញ្ហា កង្វល់ និង ការឈឺចាប់ដែលបង្ហាញដោយកុមារ ហើយយើងគាំទ្រយ៉ាងពេញទំហឹងដល់សំណូមពរជាក់ស្តែងចំនួន ១០ របស់ពួកគេដែលបានដាក់ជូនរដ្ឋាភិបាលដើម្បីការពារស្ថានភាពនានាដែលដកហូតសិទ្ធិសេរីភាពកុមារ និងដើម្បីការពារសិទ្ធិ និងសុខុមាលភាពរបស់កុមារនៅក្នុងស្ថានភាពទាំងនោះ។

យើងយល់ស្របនឹងការសិក្សាជាសកលថា ការដកហូតសិទ្ធិសេរីភាពកុមារ គឺជាការដកហូតសិទ្ធិសេរីភាពកុមារភាព និងជាទម្រង់នៃអំពើហិង្សាលើកុមារ។ យើងគូសបញ្ជាក់ពីសារៈសំខាន់នៃការយល់ដឹងអំពីការដកហូតសិទ្ធិសេរីភាព ដោយរួមមានកុមារនៅក្នុងស្ថានភាពជាច្រើន ដូចជាកុមារទំនាស់នឹងច្បាប់ កុមារនៅក្នុងពន្ធនាគារជាមួយម្តាយ និងកុមារដែលរស់នៅក្នុងមណ្ឌលជាដើម។ យើងសូមអះអាងថាកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាព មានសិទ្ធិដូចគ្នានឹងកុមារដទៃទៀតដែរ ប៉ុន្តែយើងក៏ទទួលស្គាល់ផងដែរថា ពួកគេស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ ដោយសារតែពួកគេមានតម្រូវការពិសេសដែលត្រូវឆ្លើយតបដោយអ្នកជំនាញ។

យើងទទួលស្គាល់ថាប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ក្នុងការបង្កើតប្រព័ន្ធយុត្តិធម៌សម្រាប់កុមារ ការពង្រឹងយន្តការការពារកុមារ ការធ្វើសមាហរណកម្មកុមារចេញពីមណ្ឌល និងការទប់ស្កាត់អំពើហិង្សាលើកុមារ រាប់បញ្ចូលទាំងការចូលជាសមាជិកនៃប្រទេសដែលឈានមុខគេក្នុងការទប់ស្កាត់អំពើហិង្សាផងដែរ។ តែទោះបីជាយ៉ាងណាក៏ដោយក៏នៅតែមានការងារដែលត្រូវធ្វើបន្តទៀត ហើយការសិក្សាជាសកលអាចផ្តល់នូវការណែនាំដ៏មានប្រយោជន៍ដើម្បីគាំទ្រ ដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល។

ក្នុងនាមយើងជាសមាជិកនៃសង្គមស៊ីវិល យើងមានការទទួលខុសត្រូវក្នុងការគាំទ្រដល់កុមារទាំងឡាយណាដែលកំពុងប្រឈមនឹងការដកហូតសិទ្ធិសេរីភាព។ យើងនឹងចូលរួមសហការជាមួយសហគមន៍ ដើម្បីសិក្សា និងដោះស្រាយឫសគល់នៃបញ្ហាដែលបណ្តាលឱ្យមានការដកហូតសិទ្ធិសេរីភាពកុមារនៅក្នុងកម្រិតបុគ្គល និងលក្ខណៈជាប្រព័ន្ធ ក៏ដូចជាដើម្បីកែរលំអស្ថានភាពផ្សេងៗដែលកុមារត្រូវបានដកហូតសិទ្ធិសេរីភាពកំពុងជួបប្រទះនាពេលបច្ចុប្បន្នដោយផ្អែកលើសិទ្ធិ និងបែបបទកុមារមេត្រី។ យើងនឹងអនុវត្តវិធីសាស្ត្ររួម និងអន្តរកម្មមួយ រួមមានដូចជាយុត្តិធម៌កុមារ ការការពារកុមារ ការគាំពារសង្គម ការអប់រំ ។ល។

យើងសូមប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល ក្នុងភាពជាដៃគូប្រកបដោយអត្ថន័យជាមួយកុមារ ដើម្បីទទួលបានលទ្ធផលជាវិជ្ជមានសម្រាប់កុមារទាំងអស់នៅក្នុងប្រទេសកម្ពុជា ដោយផ្តោតលើវិធានការបង្ការ និងការឆ្លើយតបចំពោះការដកហូតសិទ្ធិសេរីភាពកុមារ។ ដើម្បីចាត់អាទិភាព និងរៀបចំយុទ្ធសាស្ត្រនៃកិច្ចខិតខំប្រឹងប្រែងរបស់យើងឱ្យល្អបំផុត និងដើម្បីស្វែងរកដំណោះស្រាយដែលល្អ និងជោគជ័យបំផុត យើងនឹងចូលរួមទាំងក្នុងស្រុក និងអន្តរជាតិ រួមមានការចូលរួមសន្និសីទពិភពលោកឆ្នាំ២០២១ស្តីពីយុត្តិធម៌សម្រាប់កុមារជាដើម ។

យើងប្តេជ្ញាថាជម្រុញ និងគាំទ្រកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីធ្វើការជាមួយកុមារ ដោយគោរពសំឡេងរបស់ពួកគេ និងស្វែងរកវិធីសាស្ត្រដែលមានលក្ខណៈពេញលេញ និងមានប្រសិទ្ធភាពដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងកាលៈទេសៈរបស់កុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាព។

*សេចក្តីថ្លែងការណ៍នេះត្រូវបានរៀបចំរួមគ្នាដោយសមាជិកសង្គមស៊ីវិលខាងក្រោមដែលជាគណៈកម្មាធិការរៀបចំសម្រាប់ការផ្សព្វផ្សាយថ្នាក់ជាតិស្តីពីការសិក្សាស្រាវជ្រាវជាសកលនៅកម្ពុជា៖*

១. ក្រុមតំណាងយុវវ័យនិងយុវជន
២. សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ
៣. បណ្តាញកុមារអ្នកតស៊ូមតិ
៤. អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា
៥. អង្គការជំនួយ ផ្នែកច្បាប់នៃកម្ពុជា – សមាជិកនៃ NGO Panel for the Global Study
៦. Global Campus of Human Rights
៧. Global Initiative on Justice with Children – តំណាងដោយអង្គការ Terre des hommes

*សេចក្តីថ្លែងការណ៍នេះ ត្រូវបានចូលរួមដោយវាគ្មិន មកពីសង្គមស៊ីវិលដូចខាងក្រោម ៖*

១. Save the Children
២. អង្គការជីវិតនៅកម្ពុជា

# ៨ ឧបសម្ពន្ធ

*សេចក្តីថ្លែងការណ៍នេះ ត្រូវបានគាំទ្រដោយអង្គការសង្គមស៊ីវិលខាងក្រោមនៅក្នុងប្រទេសកម្ពុជា៖*

១. អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម
២. អង្គការសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា
៣. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
៤. អង្គការមជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ
៥. អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា
៦. សមាគមការពារសិទ្ធិមនុស្ស និង អភិវឌ្ឍន៍នៅកម្ពុជា
៧. អង្គការឃែរអន្តរជាតិប្រចាំកម្ពុជា
៨. អង្គការសម្ព័ន្ធចាប់ដៃ
៩. អង្គការកុមារក្នុងគ្រួសារ
១០. អង្គការសិទ្ធិកុមារអន្តរជាតិ
១១. អង្គការប្រឹក្សាសហគមន៍ដើម្បីអភិវឌ្ឍន៍
១២. មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍
១៣. ជំហានដំបូងកម្ពុជា
១៤. អង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា
១៥. អង្គការមូលនិធិហាការអន្តរជាតិប្រចាំនៅកម្ពុជា
១៦. អង្គការអ៊ីតាលីជួយសង្គ្រោះកុមារ
១៧. អង្គការគ្រួសារថ្មី
១៨. អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី
១៩. សមាគមហ្វារ ពន្លឺសិល្បៈ
២០. Plan International Cambodia
២១. អង្គការភូមិកុមារSOS អន្តរជាតិ
២២. Terre des Hommes Netherlands
២៣. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី
២៤. អង្គការនារីអភិវឌ្ឍន៍សេដ្ឋកិច្ច និងអនាម័យ

*សេចក្តីថ្លែងការណ៍នេះក៏មានការចូលរួមពី NGO Panel for the Global Study on Children Deprived of Liberty, ដែលមានអង្គការសង្គមស៊ីវិលចំនួន១៧០នៅជុំវិញពិភពលោកជាសមាជិក សហការដោយ Defence for Children International និង Human Rights Watchផងដែរ។ NGO Panel គឺជាដៃគូយ៉ាងសំខាន់នៅក្នុងការបង្កើតឱ្យមានគំនិតផ្តួចផ្តើម និងបញ្ចប់ការសិក្សាជាសកលនេះរួមជាមួយនឹងការតាមដានលើការអនុវត្តផងដែរ។*

NGO Panel for the
Global Study on
Children Deprived of Liberty

https://childrendeprivedofliberty.info/

---

ការផ្សព្វផ្សាយថ្នាក់ជាតិអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវជាសកលរបស់អង្គការសហប្រជាជាតិស្តីពីការដកហូតសិទ្ធិសេរីភាពកុមារ នៅក្នុងប្រទេសកម្ពុជាត្រូវបានប្រព្រឹត្តទៅនៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០២១ តាមអនឡាញដែលមានការចូលរួមពីកុមារ និងយុវជន មន្ត្រីរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ទីភ្នាក់ងារអង្គការសហប្រជាជាតិ អ្នកសិក្សា ដៃគូអភិវឌ្ឍន៍ និងសមាជិកសាធារណៈនៅកម្ពុជា បរទេស។ ការរៀបចំការផ្សព្វផ្សាយនេះបានធ្វើឡើង ដោយមានការពិគ្រោះយោបល់ជាមុនជាមួយកុមារ នឹងការចូលរួមពីក្រសួងពាក់ព័ន្ធសំខាន់ៗ។ សំឡេងទាំងនោះ រួមជាមួយសំឡេងរបស់សង្គមស៊ីវិលត្រូវបានគេរំលេចឡើងក្នុងពេលផ្សព្វផ្សាយថ្នាក់ជាតិ ដែលជាវិធីនៃការចែករំលែកព័ត៌មាន អន្តរាសន៍ និងការប្តេជ្ញាចិត្ត។

កិច្ចប្រជុំក្រុមបច្ចេកទេសដើម្បីត្រៀមរៀបចំសន្និសីទពិភពលោក២០២១ស្តីពីយុត្តិធម៌សម្រាប់កុមារ ក៏ត្រូវបានធ្វើឡើងភ្លាមៗបន្ទាប់ពីកម្មវិធីផ្សព្វផ្សាយថ្នាក់ជាតិ ដោយមានការពិភាក្សាប្រកបដោយផ្លែផ្កាជុំវិញបញ្ហាប្រឈម អាទិភាព និងការអនុវត្តជាក់ស្តែងនៅក្នុងវិស័យយុត្តិធម៌កុមារនៅកម្ពុជា និងត្រួសត្រាយផ្លូវសម្រាប់ការសម្របសម្រួលឱ្យកាន់តែល្អប្រសើរក្នុងចំណោមអង្គការយុត្តិធម៌កុមារ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងគណៈកម្មាធិការរៀបចំតាមរយៈ៖ GSCDLCambodia@gmail.com ។ ការសិក្សាស្រាវជ្រាវជាសកលអាចចូលមើលបានតាមរយៈ៖ https://omnibook.com/Global-Study-2019 និង https://nochildbehindbars.com ។

unicef for every child · YR · LEGAL AID of CAMBODIA · AYRG · CAN · CYMCR · JUSTICE WITH CHILDREN · Terre des hommes Helping children worldwide. · Global Campus of Human Rights

# ការផ្សព្វផ្សាយថ្នាក់ជាតិ អំពីលទ្ធផល នៃការសិក្សាស្រាវជ្រាវជាសកលរបស់អង្គការសហប្រជាជាតិ ស្ដីពី ការដកហូតសិទ្ធិសេរីភាពកុមារ

UN GLOBAL STUDY ON CHILDREN DEPRIVED OF LIBERTY

ថ្ងៃព្រហស្បតិ៍ទី២២ ខែមេសា ឆ្នាំ២០២១ | ២:០០-៤:០០ រសៀល

**ភាសា៖** ខ្មែរ និង អង់គ្លេស (ជាមួយនឹងការបកប្រែដំណាលគ្នា)

**ទីកន្លែង៖** លើបណ្ដាញ (Zoom)

ការដកហូតសិទ្ធិសេរីភាពកុមារគឺជាការដកហូតសិទ្ធិសេរីភាពជាកុមារភាព។

លទ្ធផលនៃការសិក្សាស្រាវជ្រាវជាសកលស្ដីពីការដកហូតសិទ្ធិសេរីភាពកុមារបានផ្តល់នូវការយល់ដឹងអំពីស្ថានភាពកុមារដែលត្រូវបាន ដកហូតសិទ្ធិសេរីភាពនៅជុំវិញពិភពលោករួមជាមួយអនុសាសន៍រឹងមាំមួយចំនួនសម្រាប់អនុវត្តដើម្បីដោះស្រាយស្ថានភាពទាំងនេះ។ ការផ្សព្វផ្សាយថ្នាក់ជាតិនេះនឹងផ្តល់ឱកាសយល់ដឹងអំពីការរកឃើញសំខាន់ៗពីអ្នកជំនាញ ឯករាជ្យដែលបានដឹកនាំការសិក្សាស្រាវជ្រាវជាសកលនេះ អំពីការគិតរបស់កុមារនៅក្នុងប្រទេស កម្ពុជាដែលត្រូវបានដកហូតសិទ្ធិសេរីភាព អំពីបទពិសោធន៍របស់អង្គការក្នុងស្រុកដែលធ្វើការ ក្នុងវិស័យនេះ និងការចាប់អារម្មណ៍ដោយរដ្ឋាភិបាល។

ព្រឹត្តិការណ៍នេះបើកសម្រាប់បុគ្គលដែលចាប់អារម្មណ៍ទាំងអស់។

**របៀបវារៈ:**

- **សុន្ទរកថាស្វាគមន៍ដោយ** ដោយ Najat Maalla M'jid តំណាងពិសេសរបស់អគ្គលេខាធិការ នៃអង្គការសហប្រជាជាតិទទួលបន្ទុកអំពើហិង្សាលើកុមារ
- **ការរកឃើញសំខាន់ៗនៃការសិក្សាស្រាវជ្រាវជាសកល** ដោយលោកសាស្ត្រាចារ្យ Manfred Nowak អ្នកជំនាញឯករាជ្យ
- **សំឡេងសង្គមស៊ីវិល** ដោយអង្គការជីវិតនៅកម្ពុជា និងអង្គការ Save the Children
- **ការលើកឡើងរបស់កុមារ** ដោយបណ្ដាញដែលដឹកនាំដោយកុមារ និងយុវជន
- **សំឡេងរដ្ឋាភិបាល**
- **សុន្ទរកថាបិទកម្មវិធី** ដោយតំណាងអង្គការយូនីសេហ្វ

បន្ទាប់ពីការផ្សព្វផ្សាយថ្នាក់ជាតិនេះ នឹងមានកិច្ចពិភាក្សារយៈពេលមួយម៉ោងស្ដីពីការត្រៀមរៀបចំសន្និសីទពិភពលោកឆ្នាំ២០២១ស្ដីពីយុត្តិធម៌កុមារ។

▶ សូមចុះឈ្មោះត្រង់កន្លែងនេះ: http://bit.ly/GSCDLCambodianLaunch

**អ្នករៀបចំកម្មវិធី**

- មូលនិធិសហប្រជាជាតិដើម្បីកុមារ ហៅកាត់ថាយូនីសេហ្វ
- អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា
- សាកលវិទ្យាល័យសិទ្ធិមនុស្ស
- អង្គការជំនួយ ផ្នែកច្បាប់នៃកម្ពុជា
- បណ្ដាញដែលដឹកនាំដោយកុមារ និងយុវជន
- កម្មវិធីគំនិតផ្ដួចផ្ដើមជាសកលស្ដីពីយុត្តិធម៌ជាមួយកុមារ តំណាងដោយអង្គការ Terre des hommes